**BMI0046**

## សម្ភាសន៍ជាមួយឈ្មោះ អ៊ុល រុន ភេទប្រុស អាយុ៥៩ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហមៈ អនុប្រធានក្រុមដាំដំណាំប្រចាំមន្ទីរ៨៧០
## មុខងារបច្ចុប្បន្នៈ មេភូមិថ្មី
## ស្រុកកំណើតនៅភូមិមានបុទ្ធិ ឃុំមានបុទ្ធិ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ
## សព្វថ្ងៃរស់នៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១០
## សម្ភាសន៍ដោយៈ ហ៊ិន សុធានី
## ០០:៤៣:១៤-០២:២១:២១
## ៣១ទំព័រ

**ចាប់ពី០០:៤៣:១៤**

រុន : ឈ្មោះ នី កន ។

ធានី : ចុះនៅម៉ាឡៃអ្នកណាគេ?

រុន : ម៉ាឡៃលោក សូ ហុង ក្រោយមកលោកសុខ ភាព ។

ធានី : សូ ហុងនឹងគាត់ខាងណាគេ?

រុន : នៅខាងនោះទេ ខាងជើងថ្នល់ គាត់កងពលដែរ ប៉ុនដល់ពូហុងនៅនោះ លោក សុខ ភាព គាត់ឡើងកងពលនៅនេះ ។ លោក សុខ ភាពទាក់ទងច្រករាល់ថ្ងៃ ។

ធានី : បន្ទាប់មកទៀតអ្នកណាគេ?

រុន : លោក សូ ហុង លោក សុខ ភាព ពីណាគេបន្ទាប់ ស៊ុម ផុនៗគាត់ចាស់មែនទែននៅ៩៣ បន្ទាប់ពីស៊ុម ផុននឹងមក តានឿន បងផ្ទះធ្វើពេទ្យ ហ្នឹងគាត់ខាងហិរញ្ញវត្ថុ ។ ស៊ុន ផុន គាត់ខាងផ្នែកទាហាន ។

ធានី : អ្នកគ្រប់គ្រងធំនៅនឹង?

រុន : គ្រប់គ្រងធំលោក សុខ ភាព ។

ធានី : បន្ទាប់ពី សុខ ភាព?

រុន : មានលោក ស៊ុម ផុននឹងឯងខាងទាហាន ។

ធានី : លោក សុខ ភាពមក មានពីណាគេជំនួសលោកសុខ ភាពនឹងទេ?

រុន : ស៊ុម ផុន បន្ទាប់មកតានឿន ។

ធានី ៖ មានអ្នកណាគេទៀត?

វុន ៖ អត់ហើយតែ៣នាក់នឹង ។

ធានី ៖ នឹងខាងកងទ័ព?

វុន ៖ បាទ! ខាងកងពល ។

ធានី ៖ ចុះខាងប្រជាជនយើង?

វុន ៖ អត់មានជំនាន់នឹង ។ បើនារីៗដឹកជញ្ជូនហើយនឹងគ្រួសារ ។

ធានី ៖ ឆ្នាំប៉ុន្មាន?

វុន ៖ អានឹងចូលឆ្នាំ៨០ ៨១ ៨២ ៨៣ ៨៤ ៨៥ រហូត ។

ធានី ៖ ដល់ឆ្នាំប៉ុន្មាន?

វុន ៖ មកដល់ទល់ឥឡូវ ។ ប៉ុននៅភូមិដូងនេះ នៅម៉ាខ្សែនេះដំបូងព្រៃ ពីក្នុងនោះមកព្រៃរហូត ។ ហើយជំនាន់ខ្ញុំមកនៅ៨១នេះ យួននៅភ្នំនេះ ប៉ុនប្រជាជននៅនេះ នារីដឹកជញ្ជូននៅនេះទាំងអស់ ហើយបើទាហាននៅខ្វាងរាប់ ទៅនៅបន្ទាយទី១ បន្ទាយទី២ អូរសំព័រ១ អូរសំព័រ២ សុទ្ធតែទាហានហើយនៅតាមនឹង សុទ្ធនារីដឹកជញ្ជូន សុទ្ធព្រៃសុទ្ធ ។ ហើយមុនសមាហរណកម្មប្រហែល២-៣ឆ្នាំ ចាប់ផ្ដើមធ្វើចំការបណ្ដើរៗរីក ដល់សមាហរណកម្ម ជំនាន់លោក ហ៊ុន សែនមកនោះ ការពិតខ្ទមចំការពោតទេ ។ ហើយដល់លោក ហ៊ុន សែនមកដល់នេះ អត់ទាន់ជឿថាផ្ទះប្រជាពលរដ្ឋនៅតាមនេះទេ ប្រពន្ធទាហាននៅតាមនេះ ។ ដល់ក្រោយមកទៀត ជំនាន់សម្ដេចឪមក បាន....សិតនេះ គាត់នាំជិះយន្ដហោះមើល គាត់បេះបើកយន្ដហោះ គាត់បើកខម្លាគចក្រ ចេញចាប់ពូខ្វាងរាប់ គាត់បង្ហាញព្រំដែនរហូតទៅដល់គីឡូ១៣ ទៅដល់ស្រុកនេះ អីចឹងបានជឿ ។ មុនដំបូងគេនិយាយថាពួកម៉ាខ្សែរៀងស្ងេកៗ អត់បានមកឃើញផ្ទាល់ ។ ប៉ុនបើកាល៧៩វេទនាមែន ខ្ញុំនិយាយឲ្យឃើញ ៧៩រត់មកអ្នកស្លាប់ច្រើន ។ មូលហេតុដែលស្លាប់អត់បាយអត់ទឹក ដែលខាងកម្ពុជាប្រជាធិបតេយ្យទាក់ទងអត់ទាន់បាន ។ ដល់ចូល៨០ ខាងកម្ពុជាប្រជាធិបតេយ្យទាក់ទងកាកបាទបានហើយ ។ បានកាកបាទខបត្ថម្ភរហូតជាពិសេសនៅបឹងត្រកួន ផ្នែកកាកបាទនៅ បឹងត្រកួននៅភូមិសង្កែរាល់ថ្ងៃនេះ ។ បានបងប្អូនប្រជាពលរដ្ឋប្រជាជនដែលរត់មកជាមួយគ្នានោះ បានផុតពីការរងគ្រោះហើយ កាកបាទក្រហមតាំងពីផ្នែកពេទ្យ តាំងពីផ្នែកសេដ្ឋកិច្ច និយាយរួមឧបត្ថម្ភគាំទ្រ ប្រជាពលរដ្ឋធូរហើយគីឡូ១៣ចេញឧបត្ថម្ភជាមួយគ្នានឹងឯង ។ មករហូតទល់សមាហរណកម្មនេះ ក៏អត់មានអត់បាយអត់ទឹកដែរ ។ ហើយរដ្ឋឧបត្ថម្ភឲ្យជាប់អង្ករតាមគ្រួសារ ដូចថាប្ដីទៅមុខរឿងហូបចុក

វិញអត់មានបេះខ្ទះទេ មានតាំងពីត្រីខ ខ្លាញ់ មី ទឹកដោះគោ និយាយរួមការឧបត្ថម្ភរបស់រដ្ឋកម្ពុជាប្រជាធិបតេយ្យវាខុសពីការជំនាន់ប៉ុលពតនៅភ្នំពេញ វាធូរធា ។

ធានី : ខុសម៉េច?

រុន : ខុសត្រង់ថាជីវភាពវាធូរជាងសម័យ៣ឆ្នាំ ។

ធានី : ជំនាន់៣ឆ្នាំម៉េច?

រុន : ជំនាន់៣ឆ្នាំ ការហូបចុកវារៀងតឹងតែងតិចដែរគេសន្សំសំចៃ ។ មកដល់ដំណាក់កាលកាកបាទមកនេះ គឺការហូបចុកវាសំបូរបែប ចង់ហូបស្អីផ្នែកទាហានក្នុងក្រុម ត្រីខទាំងឡាំង១ ហើយមីក្នុងម៉ាក្រុមម៉ាឡាំង ។ ហើយម៉ាឡាំងមាន១២កេះមី ហើយពេលទៅសមរភូមិអីមាននំចិនប៉ុននឹងកំរាស់ប៉ុននេះ ប៉ុនដើររៀងហាវហូបតែម្ខាងទេ វាមាន៤បន្ទះ ហូបមួយបន្ទះផឹកទឹកទៅអត់មានហាវមានអីទេ ។ ហើយនំនឹងផ្អែមប្រៃៗ ប៉ុនដូចឲ្យមានកម្លាំង ហើយមីកំណត់ម្នាក់ម៉ាកេះ៣០កញ្ចប់ ទៅហើយ ។ អីចឹងការដើរហើរ ដំណើរពីនេះទៅខ្លាំងរាប់ ពីមុនដើររយៈជិតម៉ាថ្ងៃ គិតទៅចូល៤ម៉ោងបានដល់ ហើយមីស្អីៗដាក់សាក់កាដូដាប់ ទឹកដោះគោ ។ ដល់ផុតពីនឹងមក ដល់សមាហរណកម្មហើយនេះ គឺរដ្ឋខាងកម្ពុជាប្រជាធិបតេយ្យចាប់ផ្ដើមឲ្យបងប្អូនប្រជាពលរដ្ឋ ខាងផ្នែកទាហានចាប់ដី វាលៗរហូតមកទល់សព្វថ្ងៃ ។ ខាងកម្ពុជាប្រជាធិបតេយ្យអប់រំ ជាពិសេសលោកអៀង សារី ថាអប់រំកូនចៅធ្វើម៉េចឲ្យបានដីធ្លីរស់នៅ យើងនៅនេះមិនមែនសមាហរណកម្មហើយ យើងមិនមែនរស់នៅខាងក្នុងបានទេ គឺយើងរស់នៅនេះ ដើម្បីការពារព្រំដែន ឯលោកហ៊ុនសែន ក៏គាត់និយាយអីចឹងដែរ ហើយអត់ឲ្យទៅនៅទេ ឲ្យនៅនេះដើម្បីការពារព្រំដែន មេកន្លែងណា គឺក្ដាប់កន្លែងនឹងកាន់កាប់នៅនឹង ផ្ទះណាផ្ទះនៅនឹង ។ មានដែនការនឹង បងប្អូនខាងផ្នែករដ្ឋកម្ពុជាប្រជាធិបតេយ្យអត់មានទៅស្រុកវិញ ។ ប៉ុនមានភាគតិចដែរ ទៅស្រុក ខ្លះគេនឹកឃើញចិត្តមិនដាច់ម៉ែឪ ។ ប៉ុនដូចខ្ញុំអីនឹកឃើញថាទៅស្រុកវាពិបាក ។ ខ្ញុំនឹកឃើញថាស្លាប់រស់នេះចុះ ហើយខ្ញុំរាល់ថ្ងៃម៉ែនៅ២ ប៉ុនម៉ែមួយវង្វេងនៅតែម៉ែខ្ញុំអត់ទាន់វង្វេងគាត់៨០ជាង ។

ធានី : នៅស្រុកណាវិញ?

រុន : ខ្ញុំនៅកំពង់ធំ ស្រុកសណ្ដាន់ ភូមិមានឫទ្ធិ ឃុំមានឫទ្ធិ ហ្នឹងស្រុកកំណើតខ្ញុំ ។ ដល់ប្រពន្ធខ្ញុំនៅខាងឧត្ដុង្គ នៅខេត្តកំពង់ស្ពឺ ស្រុកឧត្ដុង្គ ឃុំវាលពង់ ភូមិត្រពាំងទង់ ហ្នឹងខាងប្រពន្ធ ។ ហើយដល់សម្រេចថាមិនទៅនឹងឯង មុនដំបូងគ្រួសារខ្ញុំសួរថា *«ឯករាជ្យហើយយើងទៅនៅណា?»* ខ្ញុំថា *«មិនបាច់ទៅនៅណាទេ យើងកសាងជីវិតថ្មីនៅនេះ»* ។ បើយើងទៅនោះ បើទៅខាង

គ្រួសារខ្ញុំក៏អត់មានដីធ្លី ទៅខាងខ្ញុំមាន ប៉ុនខ្ញុំនឹកឃើញមិនទៅសម្រេចថាកសាងជីវិតថ្មីទាំងអស់គ្នាហើយរស់នៅនេះ ។ ហើយជាគំនិតខ្ញុំទី១រាជរដ្ឋាភិបាល បាននិយាយហើយគិតទៅដូចលោកហ៊ុន សែន គាត់និយាយ កន្លែងនៅកន្លែងណា មេណាមេនឹងអ្នកកាន់កាប់ ។ ទោះបីទាហានក៏ដោយ ប្រជាពលរដ្ឋក៏ដោយកាន់កាប់នៅនឹង ។ ហើយម្យ៉ាងជីវភាពវាអត់មានអត់ឃ្លានទេ អត់ឃ្លានតែដំបូងដែលខ្ញុំនិយាយថារឿង៧៩អ្នកស្លាប់ៗដោយសារ រដ្ឋកម្ពុជាប្រជាធិបតេយ្យទាក់ទងអត់ទាន់បាន ។ ដល់ក្រោយមកទាក់ទងបានហើយ ប្រជាពលរដ្ឋលែងរងគ្រោះដោយជម្ងឺឈឺថ្កាត់ហើយ ។ តាំងពីសមាហរណកម្មមកទល់សព្វថ្ងៃ ចិត្តអត់ចង់ទៅណាទេនៅនឹង កសាងជីវិតថ្មីនៅនឹង នាំប្រពន្ធនាំកូន ហើយបងប្អូនសាច់ជិតខាង អត់ទៅណាសម្រេចនៅនេះមករហូត ។

ធានី : ពូមកម៉ាឡៃដំបូងម៉េចដែរ ឃើញទិដ្ឋភាពនៅម៉ាឡៃម៉េច?

វុន : ទិដ្ឋភាពព្រៃៗទាំងអស់អត់មានវាល ។

ធានី : ព្រៃយ៉ាងម៉េច?

វុន : ព្រៃឫស្សី ដើមឈើធំៗ ភ្នំនៅនេះមើលអត់ឃើញទេពីមុន ព្រៃដើមឈើធំៗប៉ុនពាង ។ ជំនាន់ខ្ញុំនៅអត់សូវអីទេ វាចេះផ្អែកកងទ័ពម៉ាក្រុមចេះទៅ ពេទ្យគេឲ្យថ្នាំម៉ាដបថ្នាំការពារលេខ ៣ការពារគ្រុន ។

ធានី : ថ្នាំពីណាវិញ?

វុន : ថ្នាំយកមកពីចិន ហើយម៉ាខែលេប២គ្រាប់ លេបគ្រប់គ្នា ។ ដាច់ខែចូលខែក្រោយទៀត លេប២គ្រាប់ទៀតៗ តែអស់ប្រធានក្រុមទៅយកពីពេទ្យកងមក ។ អត់ដែលឈឺថ្កាត់ទេ ឈឺដែរ ឈឺភាគតិច បើគិតជាភាគរយ ថាប្រហែល១០ភាគរយចុះ ។

ធានី : ម៉ាឡៃដំបូងសុទ្ធតែតំបន់ព្រៃទេ ម៉េចដឹងថាកន្លែងនឹងជាម៉ាឡៃ?

វុន : ម៉ាឡៃចេះ ដែលដាក់ម៉ាឡៃភ្នំនេះគេហៅភ្នំម៉ាឡៃ ។ ប៉ុនកងទ័ពពីដើម ខាងនេះតំបន់១០២ ។

ធានី : ១០២តំបន់យ៉ាងម៉េច?

វុន : ១០២ បើនិយាយពាក្យខ្មែរយើងគេហៅស្រុកៗ១០២ ។ ហើយដល់យើងមកនៅនេះគេប្រែដាក់ស្រុកម៉ាឡៃ ឃុំម៉ាឡៃ ។

ធានី : មានតំបន់១០១អត់?

វុន : ១០១មិនដឹងណាទេ ប៉ុននៅនោះគេដាក់២០០១ ២០០២ ភ្នំដងរែក ។

ធានី : តំបន់ដែរ?

រុន ៖ បាទ! ហើយខ្ញុំអត់សូវដឹងប្រវត្តិនោះអស់ដែរ ប៉ុនតំបន់នេះគេហៅតំបន់១០២ ។

ធានី ៖ តំបន់១០២មានតាំងពីពេលណាមក?

រុន ៖ តាំងពី៧៩មក ដែលរត់ចេញពីនោះមកនៅនេះគេដាក់១០២ ។

ធានី ៖ រត់ចេញពីណា?

រុន ៖ ចេញពីភ្នំពេះមក ។

ធានី ៖ ម៉េចបានពីភ្នំពេញវិញ?

រុន ៖ ជំនាន់នឹង យួនវៃ គេឃោសនាថារស់នៅមិនបានទេយើងត្រូវតែទៅចេះមករសាត់ ចេះមកអត់បាយ ក្រហាយទឹក ។ ខ្ញុំគិតមើលចេញពីភ្នំពេញមក ខ្ញុំមកនៅអមលាំងបានប្រហែលម៉ាខែ តាម៉ុកគេហៅតា១៥ ឥឡូវគាត់ស្លាប់ហើយ គាត់ដាច់ជើងនៅ១០០២ ។ គាត់ស្លាប់ថា *"ឥឡូវពួកក្មួយៗចុះទៅលិចៗដល់ណាអ៊ី"* *"ទៅលិចដល់ណាអ៊ី"* *"ទៅណាក៏ដោយចេះទៅតាមគេទៅ?"* ។ ខ្ញុំដឹកនាំកុមារនារីអីចេញមកចេះមក ចេញពីអមលាំងមកដល់ភូមិឡូត៍ខេត្តពោធិ៍សាត់នឹង មកសម្រាកនៅនឹងឯង គេហៅពួកខ្មែរសវៃចោលអស់មិនតិចទេ ភូមិឡូត៍វៃចោលពួកនារី និងពួកកម្មករ អស់មិនតិចទេ ។

ធានី ៖ វៃនារីៗខាងណាវិញ?

រុន ៖ នៅភូមិឡូត៍ខេត្តពោធិ៍សាត់ ។

ធានី ៖ ដែលពូដឹកនាំទៅនឹង?

រុន ៖ ដែលខ្ញុំដឹកនាំចុះមក ។

ធានី ៖ ដឹកនាំចុះមកត្រូវគេវៃចោល?

រុន ៖ បាទ! ចាប់វៃចោលអស់ច្រើនណាស់ ប្រហែលជាថាមិនត្រូវដែរ ។ ដល់ខ្ញុំនៅនឹងគេសួររកថាអ្នកណាអ្នកដឹកនាំ អ្នកណាមេធំ ប៉ុនពួកនឹងចេះលាក់ខ្ញុំដែរ ។ គេថា *"អត់ដឹង"* *"អត់ដឹងម៉េចក៏មកស្រួច"* ។ ដល់ចាប់អស់ម៉ាចំនួន ស្រាប់តែកម្លាំងតាចៀម គេដឹកនាំមកជួបពួកខ្ញុំនឹង បានពួកខ្ញុំចេញមកបណ្តោយ ។ គិតទៅគេហៅភូមិព្រៃកដឹកវៃចោលច្រើនណាស់ ហើយអាចូចមួយធ្វើបាបនារី ហើយវៃចោលនារី អាចូចនឹងពួកនឹងបាញ់ចោល ។ បានផុតពីនឹងគេថាទៅទៀតយើង បានចេញមកដល់ផុតក្បាលខ្មោចមក ចេះមកៗដល់វាយូរហើយភ្លេច ។ មកដល់អន្លង់មៀន អ៊ំថា *"ក្មួយអើយអ្នកណាអត់តាន់ហូបបាយ ទៅអ៊ំៗសហករណ៍"* ។

ធានី ៖ សហករណ៍នៅណា?

រុន ៖ សហករណ៍គាត់នៅនឹងនៅអន្លង់មៀន ។

ធានី ៖ អន្លង់មៀននៅណា?

រុន : អន្លង់មៀននៅនឹងបាត់ដំបង មកដល់អន្លង់មៀនមីងៗចាប់ផ្ដើមនៅនឹង ហើយខ្ញុំចាប់ផ្ដើមបែកប្រពន្ធពីនឹង ខ្ញុំមកនៅទាក់ដ្អើម ។ មកសម្រាកនៅទាក់ដ្អើមមួយយប់ បានចេញមិនដឹងណាណែ ខ្ញុំចេះមកៗបាន ។ ដល់ពេលខ្ញុំមកវ៉ៃនៅផ្លូវជាតិលេខ១០នោះ នឹងដែលភូមិទួលខាងលិចដ្អីង ខ្ញុំរបួសៗនេះរាល់ថ្ងៃនេះ សៀតផ្កា ។

ធានី : របួសដោយសារអី?

រុន : របួសដោយសារអំបែកគ្រាប់អា៦០ កាំភ្លើងត្បាល់អុកអាធន់តូច ។ របួសនឹងបានខ្ញុំរត់ចេញ បានខ្ញុំបកទៅកើតវិញ ទៅដល់សាលាស្រុកក្រញ៉ូងតាសាញ ។ ហើយដល់មន្ទីរពេទ្យ៣៧ ដេសេអានោះជ្មោងបាញ់ដាក់មន្ទីរពេទ្យ ខ្ញុំរត់ចេញ មកមិនដឹងទៅណាណែ មកតាមព្រំដែន របូតព្រំដែនពីសំឡូតមកធ្លាក់នៅ ឡើងភ្នំស្អីខ្ពស់ឃ្លាតគ្នាតែ១០ម៉ែត្រមើលគ្នាអត់ឃើញ ។ ថ្ងៃត្រង់ចេះភ្នំខៀវអី ហើយមានម៉ាផ្លូវដើរ ហើយខ្ញុំតាំងពីព្រឹកឡើងភ្នំ ដល់ពេលចុះថ្ងៃល្ងាច ចុះផុតថ្ងៃលិច ។ ខ្ញុំចេះដើរៗមកដល់កន្លែងការពារគេហៅអូរព្រៃជ័រនោះ មានដើមធូរ៉េន ផ្លែប៉ុនៗនេះ មកដល់ត្រឹមនេះខ្ញុំដាច់បាយ ប៉ុនអំបិលខ្ញុំអត់ឲ្យដាច់ ខ្ញុំចេះម៉ាកញ្ចប់ប៉ុននេះ ខ្ញុំដាក់មកដល់ដំឡូងមី ខ្ញុំទៅដក គ្រាន់ចេញទៅមីន៦-៧ ខ្ញុំចាប់ផ្ដើមទៅដោះៗអស់ហើយ ហៅបងប្អូនប្រជាជនខ្លះ កម្មករខ្លះឲ្យទៅដកៗ ។ *“បងឯងដកអស់ហើយ?”* ខ្ញុំថា *“ខ្ញុំដកអស់ហើយ”* បានគេទៅដកផុតឆ្អើល បានចេញដំណើរមក ខ្ញុំធ្លាក់មកប៉ៃលិន មកឡាក់៦៩ ។ មកដល់ប៉ៃលិននោះ យួនលេងមកពីកើតមកទៀត តាមផ្លូវជាតិលេខ១០ ហើយខ្ញុំនៅរបួសនៅឡើយ អត់ទាន់ជា ហើយនៅរុំថ្នាំពេទ្យ គេចេះឲ្យមកតាមផ្លូវ ចេះឲ្យថ្នាំឲ្យផ្សះមក ខ្ញុំលេបបណ្ដើរៗមក ។ មកដល់ប៉ៃលិននេះឯង នៅអូរអីនៅវល្លិ៍តាំងស៊ូ គេថា *“អ្នកណាអត់របួសទៅការពារកម្លាំង បើមិនការពារកម្លាំងទេ អ្នកមកពីក្រោម មកឡាក់៦៩មកងាប់អស់ហើយ”* បានមេទាហានលោក អ៊ី ឈាន រៀនចំកម្លាំងទៅការពារបានចេញមក បានខ្ញុំមកធ្លាក់កំរៀង ។ មកដល់កំរៀង ខ្ញុំគេបញ្ជូនមកពេទ្យ អានឹងដល់ទិសដៅស្រួលបួលហើយ កម្លាំងពួកខ្ញុំទៅភ្នំកុយ ។ ដល់យួនលេងមែនទែន អ៊ី ឈាន ប្រុងកំទេចបេ៤០ តំរៀបប៉ុនគ្រែគេបោះបង្គោលឡើងកំពស់នេះអាបេ៤០អាវែងៗ ប្រុងកំទេចកាំភ្លើងចោល ខ្លាចរត់អត់រួច ។ ដល់កម្លាំងពួកខ្ញុំម៉ាវរសេនាតូច មានអីអាមួយយក អា២យកៗគិតទៅដល់ថ្នាក់ក្នុងមួយក្រុមបេ៦-៧ដើម ប្រធានពួកប៉ះត្រង់ណាក្នុងម៉ាពួក៣នាក់អាការតែម៉ាដើម បេ២ដើម ។ ដល់ទៅវ៉ៃនៅភ្នំកុយ ដល់ថ្នាក់យួនគេអត់ហ៊ានត គេហៅពួកកងបេរូ ។ ដល់ខ្ញុំជារបួសហើយ ខ្ញុំទៅវ៉ៃភ្នំកុយ ធ្លាក់ទៅសាលាក្រៅ ត្រង់កំពង់ឡៃ ដល់ក្រោយមកយួនបុកមកទៀត ខ្ញុំរត់ចេញមកនៅខ្លែមៗ បានម៉ាឆ្នាំជាង ។ ចេញពីខ្លែមមកទៀត បានមកនៅគេហៅអូរអន្លក់ ហើយកាលនោះខ្ញុំ

ប្រធានក្រុម ។ កាលនៅអូរអន្ទក់រុញតែកងអនុសេនាតូចពួកខ្ញុំនឹង ហើយនៅមុខគេៗនឹងសប្បាយស៊ីចំណាប់ និយាយពីសាច់ដាក់មីន ហើយនឹងបាញ់ ។ អត់មានថ្ងៃណាហូបទទេរទេតែសាច់រហូត ។ បានចេះដេញៗមក មកនៅវាលស្បូវទី៣ ដល់ក្រោយមកទៀតមេៗហៅប្រជុំថាយើងសម្រេចមកនៅ១០២ តំបន់នេះពីដើមគេហៅ១០២ ។ ហើយមកនៅតំបន់១០២នេះ យើងត្រៀមការពារស្រេច ខ្លាចកម្លាំងពួកតាកនោះគេអត់ឲ្យមក ។ ហើយពួកខ្ញុំមក បើនិយាយពីកាំភ្លើងដៃ សុទ្ធតែពេញហើយម៉ាទ្រូងពេញ១២០ និងបង់៣០ទៀត១៥០ ក្បាល៦០ឲ្យនារីកាន់ម្នាក់២-៣គ្រាប់ ហើយ៤០កំណត់ម៉ាយករួច៧គ្រាប់ម្នាក់៨០ ៨១ ហើយនឹង៦៧ ដូច៨១ ប៉ុនវារីកាណុង តែវាខ្លី យកមកស្រេច ។ គ្រាន់តែមកដល់ខ្ញុំឆ្លងអូរនឹងហើយ កម្លាំងពួកតាកនោះ អ្នកស្គាល់គ្នាដែរ «គេថាឈប់បងឯងទៅណា» «ហ៎!អត់ឲ្យទៅទេ» ខ្ញុំថា «មិនឲ្យទៅក៏ត្រូវតែទៅ» ខ្ញុំថា «ឥឡូវថាខ្មែរកុំវ៉ៃខ្មែរ ខ្ញុំដាក់និយាយអីចឹងហើយ បើថាវ៉ៃខ្មែរពិបាកណាស់» បានគេថា «បងឯងទៅណា?» ខ្ញុំថា «ខ្ញុំទៅ១០២ ខ្ញុំទៅទាល់តែបាន បើមិនបានមិនសុខចិត្តទេ» ហើយម៉ាវរសេនាតូច គិតទៅចេញមកទាំងអស់ ខ្ញុំចេញពីនោះមកៗដល់កន្លែងហុងនេះ កាលនោះហុងអត់ទាន់ទៅនៅ១០០១ ១០០២ ហើយភាព អនុហុង១ មុនដំបូងហុងប្រធាន ហើយភាព គាត់អនុ ។ ដល់នៅនេះ គេថាអត់ឲ្យទៅណាទេ ពួកមកពីត្បូងមក ឲ្យនៅនឹង លោកឈឹម មន្ទីកងវរៈ ឥឡូវគាត់ចៅហ្វាយស្រុកហើយ ។ លោក ឈឹម មន្ទីមុនចៅហ្វាយស្រុកនេះ គាត់ក្រោយទៅនៅថ្មពួក ក្រោយទៅនៅការិយាល័យខេត្តហើយរាល់ថ្ងៃ ។ ដល់ក្រោយមកទៀត នៅមិនបានទៅ ពួកខ្ញុំម៉ាវរសេនាតូចគេឲ្យទៅនៅបន្ទាយទី២ ។ ខ្ញុំចាប់ផ្ដើមរៀបគ្រួសារៗនោះហើយរស់នៅនឹង ដល់ក្រោយមកទៀត យួនបុកនៅម៉ាសារទៀត ខ្ញុំទៅនៅដីថៃទាំងអស់គ្នាទៅនៅដីថៃទាំងអស់នៅប៉ុន្មានឆ្នាំ៨៥ ៨៦ ៨៧ ៨៩ ៨៩ ៩០ យូរដែរ ។

ធានី : ពូថាមកដល់១០២គេកកើត?

វុន : ខ្ញុំចេញមកដល់១០២នេះហើយ មុនដំបូងនៅនេះ បន្ទាប់ពីនៅនេះ ខ្ញុំមកនៅបន្ទាយទី២ ហៅអូរសំព័រ២ ។ ដល់ខ្ញុំនៅនឹង ខ្ញុំពិការហើយ ។ ដល់ពិការគេឲ្យខ្ញុំនៅក្រោយ ។ មើលមុនដំបូងអត់ទាន់ពិការទេ ខ្ញុំទៅនៅសមរភូមិខាងថៅកែយ៉ រ បន្ទាយយួន នៅវ៉ៃនៅនឹង កន្លែងខ្ញុំនៅបន្ទាយទី២ ។ ដល់ក្រោយមកទៀត ខ្ញុំប្រចាំការនៅក្បាលហុងៗខ្ញុំរបួសនៅក្បាលហុងខ្ញុំដេកពេទ្យៗដាហើយ បានមេៗគេបង្ខំឲ្យរកគ្រួសារ ។ ខ្ញុំចាប់ផ្ដើមរៀបគ្រួសារឆ្នាំ១៩៨១ខ្ញុំពិការ ដល់ឆ្នាំ១៩៨២ បានមានកូនមានចៅ ខ្ញុំអត់ទៅណាទេ ខ្ញុំនៅដល់នេះខ្ញុំធ្វើអនុភូមិគេពិការធ្វើអីអត់កើត គេឲ្យធ្វើអនុភូមិក្តាប់គ្រួសារទាហាននឹងឯង ។ ដល់១៩៨៥ ខ្ញុំយួនដេញ

ខ្ញុំរត់ចូលដីថៃ ចំងាយពីនេះទៅ៧គីឡូដី ។ គេដាក់កន្លែងដែលរស់នៅ ដាក់៨៥ ជំរំ៨៥ ។ ខ្ញុំនៅនោះនៅខាងសេដ្ឋកិច្ចវរសេនាធំ គេចាត់តាំងជំនួយការវរៈសេនាធំខាងផ្នែកសមាជិក ។ ដល់ពេលចូលឆ្នាំ១៩៩០ ផែនការគេវៃ យួនដកចេញអស់ ផែនការគេមកនៅដីយើងវិញ ផែនការគេកំណត់៦ខែ ប៉ុនវៃតែ១ខែកន្លះទេបានមកនៅនេះវិញ ។ ដល់ក្រោយមក នៅព្រៃ នៅឡើយទេ ព្រៃមិនទាន់ស្ងុកទេ វាលក្តុំហើយ ។ ខ្ញុំអត់មានធ្វើអីទេ ចេញពីនោះវិញ គេសួរ ដេញដោលខ្ញុំដែរ ហើយមេៗវរសេនាធំសួរថា *"ឥឡូវធ្វើអីនៅនោះ?"* ខ្ញុំថា *"អត់មានធ្វើអីទេ ធ្វើរឿងកាន់កាប់ភូមិខ្ញុំអត់ចង់ធ្វើ"* រហូតដល់មេៗពីមុនគាត់ខឹងខ្ញុំ ថាតួនាទីភារកិច្ចពីមុន មេក្រុមទាហាន ហើយមកដល់ក្រោយមកហេតុអីអត់ចង់ធ្វើ ។ មុនខ្ញុំអនុភូមិនៅកាន់ប្រពន្ធ ទាហាន ដល់ក្រោយមកចេញមកពីដីថៃ ខ្ញុំអត់ធ្វើទេ ។ ឲ្យធ្វើអីក៏ខ្ញុំមិនធ្វើ បើហត់ពេក ។ មក ដល់បច្ចុប្បន្នក្រោយនេះ មេៗបានអប់រំឲ្យរកដីធ្លីរស់នៅ ខ្ញុំក៏បាបប្រឹងប្រែងរកដីធ្លីបានមួយ ចំនួន ។ មកដល់សមាហរណកម្ម បានកាប់វាលអស់ព្រៃតាមនេះ ហើយកាលនោះនៅផ្តល់ម្ហូប អាហារនៅឡើយទេ ផ្នែកតាអៀង សារី នៅផ្តល់ជាអង្ករ ជាអីបើកឲ្យ ខោអាវ ម្ហូបចំណី តាំងពីប៊ីចេង អង្ករ ស្ករ ទឹកដោះ បើកឲ្យរហូត ។ មកដល់សមាហរណកម្មផ្តាច់ផុតហើយ លោកហ៊ុន សែនមក ខ្ញុំគេឲ្យនៅជួយធ្វើផ្ទះមីងៗ ខ្ញុំពិការខ្ញុំទៅមុខអត់បាន ។ ហើយអាតួនាទី សមាជិកវរសេនាធំ ខ្ញុំផ្តាច់អស់អត់មាននៅទេ ។ ដល់ជួយធ្វើផ្ទះមីងៗហើយ ខ្ញុំស្ទុកស្ទាញ់ ពេកនឹកឃើញថាគ្មានថ្ងៃទំនេរសោះ ចាប់ផ្តើមសុំតាមុតខាងភស្តុភារនោះ ថា *"បងខ្ញុំទៅមុខ ហើយ"* *"ហឺ!រុនឯងទៅ បានអ្នកណាធ្វើផ្ទះឲ្យគេ"* *"ហេ៎!ខ្ញុំអត់នៅទេ ខ្ញុំទៅហើយ"* ខ្ញុំទៅនៅ ខ្វាងវាប់ជាមួយខ្មោចបងផន វរសេនាធំ ។ ដល់តានី គាត់ដឹងស្រែកគេអូ មកប្រាប់ដេញឲ្យមក ផ្ទះវិញ ដេញឲ្យមកនៅនេះវិញ ។ ខ្ញុំរស់នៅនឹងឯងរហូតមកដល់សព្វថ្ងៃ សមាហរណកម្ម ហើយ ខ្ញុំចេះតែគេចៗពីការងារភូមិគេចអត់រួច ទៅមកៗជាប់ដដែលទល់ឥឡូវនេះ ។តាអែម គេឃាត់ទៅគ្មានស្អីលើខ្ញុំ ដល់លើខ្ញុំគ្មានស្អីបាតដៃទទេរ ស្អីក៏អត់មាន តែបញ្ជីអីទទេរ អត់មាន ចំនួនប្រជាពលរដ្ឋខ្ញុំទៅយកពីឃុំមកវិញ ។

ធានី ៖ ចុះពូទើបធ្វើ?

រុន ៖ ខ្ញុំពីដើមអនុ ដល់ប្រធានគេដុតចោលអាបញ្ជីអស់គ្មានស្អី អីចឹងបានខ្ញុំជំរើន អត់ទាន់ដឹងចំនួន ប្រជាពលរដ្ឋប៉ុន្មានទេ ប៉ុនខ្ញុំយកឆ្នាំមុនរាយការណ៍គ្រប់ផ្នែកស្ថាប័ន ប៉ុនរយៈប្រហែលម៉ាខែ ២ខែដឹងចំនួន ប្រជាពលរដ្ឋប៉ុន្មានៗនៅក្នុងភូមិ ។

ធានី ៖ ដំបូងពូថានៅភ្នំពេញឆ្នាំ៧៩?

រុន ៖ ខ្ញុំនៅភ្នំពេញអានោះកាលពី៧៩មកទល់រត់ចេញពីភ្នំពេញមក ។

ធានី ៖ កាលមុនពូនៅស្រុកកំណើត ហើយម៉េចបានមកនៅនេះ?

រុន ៖ អានេះចេះ ខ្ញុំនិយាយកាត់ទេ ពីមុននោះ បើខ្ញុំនិយាយទៅវាវែងឆ្ងាយណាស់ តាំងពីទាហានជំនាន់ខ្មែរក្រហម បើនិយាយពីអតីតវាយូរណាស់ គិតទៅតាំងពីអាយុខ្ញុំ២០ មកទល់ឥឡូវអាយុ៥៩ ។ អាយុ២០គេរើសទ័ពជំនាន់ហ៊ូ នឹម ហ៊ូ យន់ ជំនាន់រដ្ឋប្រហារលន់ នល់ ខ្ញុំនៅទាហាន ។ ខ្ញុំមកនៅវ៉ៃនៅសមរភូមិកំពង់ធំ នៅវ៉ៃនឹង ខ្ញុំចុះឆ្នាំ៧២ មកដល់ទួលកាំភ្លើងនៅបារាយណ៍តាំងគោកនេះ ។ បើមិនជឿមើល ការខ្ញុំឡើងញាក់ ប្រតិបត្តការណ៍ចលនាទី២នៅសៀមរាប ។ ខ្ញុំខ្លាចខ្ញុំ កាំភ្លើងឡើងហៀរកែង ដូចទឹកហូរ ហើយអាអឹម៧៩គ្រាប់ប៉ុនៗនេះមានគ្នាខ្ញុំខ្លះបាក់ទឹកចិត្តរត់ ខ្ញុំនឹកឃើញម៉េចបែកប៉ុននឹង ធ្វើម៉េច...ពង្រឹងទស្សនៈខ្លួនឲ្យបាន ។ ខ្ញុំពង្រឹងបាន រហូតដល់ជំនាន់វ៉ៃជាមួយយួន ដល់ចលនាទី២ជិតដល់កំពង់ធំប្រហែល១០០ម៉ែត្ររលាយអស់ៗ ខ្ញុំចាប់ផ្ដើមរហូតនៅជុំវិញកំពង់ធំអី ។ អីចឹងបានថាក្រឡុងក្រលៀតគៀនកោះអស់ ឡើងពូនឹងឆ្ងល់ថាអីប៉ុនស្គាល់ម៉េច ម៉ាជុំវិញកំពង់ធំ...... ។ ថាខ្ញុំវាឆ្អែតហើយនោះដូចតំបន់ព្រៃអាចម៍.... ខ្ញុំដឹងអត់ហើយ ។ ខ្ញុំមុនដំបូងនៅ៩០៧ ក្រោយមក ទៀតដល់ទៅវ៉ៃនៅ....នារីរបួសត្រូវដៃ ឲ្យនារីគ្នាវាៗអត់យក កាលនោះវ៉ៃរួមជាមួយនារី ទាល់តែបង់ឯង ខ្ញុំនឹកឃើញថាបើមិនយកឯាប់ តែវ៉ៃចាញ់គេធ្វើបាបនារីឯាប់ ខ្ញុំចាប់ផ្ដើមបីនារីមកដល់៦០ៗឲ្យពួកនោះយក ថាអត់យកទេមកដល់៨០អាកាំភ្លើងត្បាល់៨០មីលីម៉ែត្រ ខ្ញុំលើកបីទៅដល់ស្នាក់ការគេ បានគេយកទៅ ។ ដល់វ៉ៃអានឹងហើយបាន៥-៦ខែ នារីជាបានសួរមករកខ្ញុំយកធ្វើជាប្ដី ហើយកងវរថាមិនកើតទេ "រុនឯងទៅនៅកងពិសេស" "ទៅនៅណាក៏បានដែរ ខ្ញុំ ថាឲ្យតែបងឯងឲ្យទៅនៅ" ខ្ញុំគេបញ្ជូនឲ្យទៅនៅកងពិសេស១០៧ ។ ចេញពី៤០៤ហើយខ្ញុំទៅនៅកងពិសេ១០៧ មានតែម៉ាអនុសេនាធំទេ ។

ដានី ៖ នៅកងពលណា?

រុន ៖ អត់មានកងពលទេ កងតំបន់ៗ តំបន់នៅកាលនោះហៅភូមិភាគ៣០៤ វាមានខេត្តកំពង់ធំព្រះវិហារ សៀមរាប ។

ដានី ៖ កំពង់ចាម?

រុន ៖ បាទ! កំពង់ចាមមួយទៀត៤ខេត្ត ហើយកាលនោះតាពក គាត់កាន់កាប់ត្រឹមគណៈតំបន់ ។ ឥឡូវគាត់រស់នៅ ខូចបាត់ដឹងឥឡូវ ។

ដានី ៖ គាត់ស្លាប់ហើយ តាំងពី៩០ប៉ុន្មាន សមាហរណកម្មហើយ ។

រុន ៖ ស្លាប់ហើយ ។ ដល់មើលនៅជុំវិញនៅទល់៧៥ៗ បានគេបញ្ជូនខ្ញុំទៅនៅភ្នំពេញ ហៅពួកកងពិសេស ។ នៅភ្នំពេញនៅកាត់ដេររដ្ឋៗ មិនមែននៅខាងកាត់ដេរ នៅខាងសម្ភារៈរដ្ឋ ប្រមូល

សម្ភារៈរដ្ឋ ដល់ក្រោយមកគេផ្លាស់ទៅនៅធ្វើទំប៉ុង ។ ចេញពីធ្វើទំប៉ុងទៅ នៅកាត់ដេរ ។ ចូលកាត់ដេរនៅបានម៉ាឆ្នាំទេ...។ ដល់ពេលថ្ងៃមួយនោះពួកមន្ទីរ គេខឹងខ្ញុំម៉េចទេ គេដកខ្ញុំនៅទួលអំពិលនៅជិតព្រែកក្តាម ហើយដល់ពេលកន្លែងដែលខ្ញុំរស់នៅផ្សារដើមគរ រៀនសូត្រអីយកខ្ញុំទៅវិញ ដល់ក្រោយមកយួនបុករត់ចេញមក ថាមកដល់អមលាំង ។ បើនិយាយប្រវត្តិវាដូរចត់ឆ្ងាយដែរ អត់បាយក្រហាយទឹកដែរ ។

ធានី : ការពេលប្រមូលសម្ភារៈរដ្ឋនៅខាងអ្នកគ្រប់គ្រង?

វុន : អានឹងខាងផ្នែកក្រសួងការបរទេស ។

ដានី : អ្នកណាគេ?

វុន : ខាងផ្នែកក្រសួងការបរទេស តាអៀង សារីអីនឹង គាត់អ្នកកាន់កាប់ ។

ដានី : ម៉េចបានពូដឹង?

វុន : ចុះមេៗធំ គ្មានអ្នកណាមានតែគាត់នឹង ។ អានឹងប្រមូលដូចថាសម្ភារៈតាមផ្ទះថ្ម ដែលគេជម្លៀសចេញអស់ហើយ ដូចម៉ាស៊ីនដេរ ប្រមូលទុកដាក់ឃ្លាំងទុកផ្សេង តាំងពីម៉ាស៊ីនដេរម៉ាស៊ីនភ្លើង ម៉ាស៊ីន បូបទឹក និយាយរួមសម្ភារៈទាំងអស់ តាំងពីចានឆ្នាំង របស់ដែលគេលក់ដូរពីមុនៗនឹង ប្រមូលទុកម្តុំ ។ ដល់ហើយគេបើកចែកចាយតាមផ្នែកក្រសួងមន្ទីរគេ ក្រសួងមន្ទីរណាដែលខ្វះខាតគេស្នើទៅថ្នាក់លើសម្រេចមក បើក ។ កាលនោះខ្ញុំនៅបើកសម្ភារៈដែរ ដល់ក្រោយមកបានខ្ញុំនៅកាត់ដេរ ។

ដានី : ពូធ្វើប្រធានគេ?

វុន : ខ្ញុំអត់ទេ ខ្ញុំនៅក្រោមការគ្រប់គ្រងគេទាំងអស់ ប៉ុននៅសម្ភារៈរដ្ឋខ្ញុំផ្នែកប្រធានក្រុម ។ ប៉ុនខ្ញុំមកនៅកាត់ដេរនេះ គឺខ្ញុំអនុគេដែរ...។

ដានី : នៅក្រសួងការបរទេសដែរ?

វុន : បាទ! កាត់ដេររដ្ឋ វានៅក្នុងមន្ទីរធំគឺ៨៧០ ។

ដានី : នៅកន្លែងណាមន្ទីរ៨៧០?

វុន : នៅកន្លែងជិតសម្តេចនៅនឹង ជិតវាំង ខាងលិចវាំង មកខាងជើងវាំងនោះ អានឹងកន្លែងមន្ទីរ៨៧០វា ហៅក-៧ ។

ដានី : ពូធាប់ចូលក្នុងនឹងដែរ?

វុន : ចូលតើ ប៉ុនមិនដែលចូលទៅកន្លែងស្តេចដង អត់ដែលចូលកន្លែងស្តេចគង់ ។ បើមន្ទីរ៨៧០ខ្ញុំចូល ពីព្រោះតួនាទីខ្ញុំនៅផ្សារដើមគរនេះ មានការខ្វះខាតអី ព្រោះមន្ទីរធំតែមួយ ដូចថាកាត់

ដេរនេះផ្នែកតូចទេ ។ ដូច្នេះ ខ្ញុំមានសិទ្ធិទៅយកដែរផ្នែកមន្ទីរគេឲ្យរទេះសេះបាន២ ខ្ញុំមើលតែមន្ទីរណាអត់ សរសេរសំបុត្រមួយទៅយកកន្លែង៨៧០ ខ្ញុំបររទេះសេះទៅសម័យ៣ឆ្នាំ ។

ធានី ៖ យកអីគេនៅមន្ទីរ៨៧០ ?

វុន ៖ យកអង្ករ យកអីរបស់របរដែលយើងចាំបាច់ដូចថាដែលយើងត្រូវធ្វើដូចស្អី១ ដូចជាឈើ... យកពី៨៧០ផ្ទាល់ ជួនកាលគេយកឲ្យនឹងមន្ទីរទៅ ។

ដានី ៖ ៨៧០ធំទេ?

វុន ៖ កន្លែងច្បាប់ ។

ដានី ៖ ពីណាខ្លះធ្វើការនៅនឹង?

វុន ៖ មេ១ តាអៀង សារី, តាសុន សេន, ខៀវ សំផន, ប៉ុល ពត, នួន ជា គ្រប់គ្រងកន្លែងនឹង ។

ធានី ៖ ពូធ្លាប់ឃើញគាត់ទេ?

វុន ៖ ខ្ញុំបើតាប៉ុល ពត ខ្ញុំមិនធ្លាប់ឃើញច្បាស់ សុន សេន ក៏អត់ច្បាស់ អៀង សារីបានច្បាស់ពីព្រោះអៀង សារីគាត់នៅនេះជាប់ ក្តាប់នេះ ។

ធានី ៖ កាលជំនាន់៣ឆ្នាំ ពូធ្លាប់ឃើញគាត់ កាលនៅមន្ទីរ៨៧០ ?

វុន ៖ ធ្លាប់ឃើញគាត់ដែរ ឃើញម្តង១ ប៉ុន្មមកច្បាស់នៅនេះ ។

ដានី ៖ ចុះគណៈមន្ទីរ៨៧០ពីណាគេ?

វុន ៖ មានស្លាប់បាត់ហើយ ក្មេងឈ្មោះបាត់ តាលឹម គាត់ស្លាប់អានឹងគាត់តួនាទីកាន់កាប់មើលឧបត្ថម្ភ ។

ដានី ៖ តាលឹមគាត់អ្នកនៅណា?

វុន ៖ អត់ដឹងទេ អត់ដឹងអ្នកនៅណាទេ ។

ដានី ៖ អ៊ំគាត់អ្នកធ្វើច្បាប់ធ្វើអីទៅមន្ទីរ៨៧០ ?

វុន ៖ ទៅពិភាក្សាគ្នានៅនឹង មន្ទីរធំ ផ្នែកទូទាំងប្រទេស ។ ហើយដល់ខ្ញុំមកនៅគាត់ដេរ ខ្ញុំដាំដំណាំហើយចិញ្ចឹមជ្រូក ។

ដានី ៖ ផ្គត់ផ្គង់មន្ទីរ៨៧០ដែរ?

វុន ៖ បាទ! ផ្គត់ផ្គង់មន្ទីរ៨៧០ផង ពេទ្យ១៧មេសាផង ហើយផ្នែកកន្លែងខ្ញុំគាត់ដេរផង ។ ហើយបន្លែក៏អីចឹងដែរវា៣ផ្នែក ។

ដានី ៖ ពូមកពីខាងឧត្តរ ខាងជាមួយខ្មៀ ប៉ង់មកនឹងដែរ?

វុន ៖ 	គាប៉ន់ មុនដំបូងនៅជាមួយខ្ញុំដែរ គាត់គ្រប់គ្រងនឹងដែរ ប៉ុនដល់ក្រោយមកគេដកខ្ញុំអត់ដឹង ។ កាលនៅមន្ទីរនោះមុនដំបូង ខ្ញុំនៅជាមួយកាត់ដេរនោះ អីត្រង់ណាទេភ្លេចឈ្មោះបាត់ ផុតឈ្មោះតានឹងបានតាប៉ន់ៗ ក្រោយមកទៀតបាននារីភ្លេចប្រធានក្រោយរត់យួន ។

ដានី ៖ 	តាប៉ន់នៅមន្ទីរ៨៧០ដែរ?

វុន ៖ 	គាត់នៅមន្ទីរ បាទ!ចេញពីនោះមកនៅកាត់ដេរ គ្រប់គ្រងកាត់ដេរ ដល់ក្រោយមកថាតាប៉ន់ក្បត់ម៉េចៗខ្ញុំអត់ដឹងរឿងដែរ បាត់តាប៉ន់ បាត់អស់២នាក់ ហើយនៅនារីខន ដែលមុនរត់យួន នារីខនអ្នកគ្រប់គ្រងមន្ទីរកាត់ដេរ ។

ដានី ៖ 	នារីខន គាត់មកពីណា?

វុន ៖ 	អត់ដឹងដែរ ។ មុនដំបូងតាគុនៗបានតាប៉ន់ៗ ហើយបាននារីខន វា៣ដំណាក់ តាគុនក៏បាត់ដែរ ។

ធានី ៖ 	តាគុនមុនគេ?

វុន ៖ 	បាទ! តាគុនមុនគេ ។

ធានី ៖ 	គាត់ប្រធានកាត់ដេរ?

វុន ៖ 	បាទ!

ដានី ៖ 	ចុះនារីខន?

វុន ៖ 	នារីខន រហូតដល់យួនដេញរត់មក ។

ដានី ៖ 	ឥឡូវគាត់នៅ?

វុន ៖ 	អត់ដឹងដែរ មិនដឹងទៅណាទេ ហ្នឹងការខ្ញុំរស់នៅភ្នំពេញ ។

ដានី ៖ 	ដាំបន្លែយើងដាំបានល្អ?

វុន ៖ 	ដាំបានល្អរបស់ខ្ញុំដែរតើ ម៉ាខែបាន៣គោនជាង ប៉ុនមានអីលឿនជាងគេ មានតែឃ្លោក ។

ដានី ៖ 	សម្រាប់អីៗហូប?

វុន ៖ 	សម្រាប់ខបត្តម្ភផ្នែកក្រសួងកាត់ដេរ ពេលសល់ជូន៨៧០ៗខ្វះ ផ្នែកមន្ទីរតូចនឹងឯងគេរាយការណ៍៨៧០ គេមកដាំលឿនជាងគេមានតែឃ្លោកៗឲ្យតែឃើញក្តិប តែប៉ុននេះ តែមួយអាទិត្យ ។ អាឃ្លោកផ្លែវែងៗអាមួយ៣-៤គីឡូ លឿនណាស់អានោះបានខ្ញុំកើតការប្រឹបូកប្រិបល់ខ្លាំងអី ខ្ញុំបានកើតពីបញ្ហានឹង សេដ្ឋកិច្ចបានខ្ញុំអត់សូវមានការលំបាកនោះ ។ បើសិនខ្ញុំធ្វើអីមិនរីកចំរើន ខ្ញុំច្បាស់មិនដឹងម៉េចទេ មិនបានរស់ដូចសព្វថ្ងៃដងក៏មិនដឹង សម័យ៣ឆ្នាំ ។ រហូតមកដល់ខ្ញុំនៅទ័ពក៏អីចឹងដែរ ។

ដានី ៖ 	ចុះជំនាន់៣ឆ្នាំ ពូដែលធ្វើអីខ្វះដូចថាពូគិតបើយើងមិនបានរីកចំរើនមិនបានរស់?

វុន ៖ ឥឡូវគិតចេះ ជំនាន់នឹងធ្វើអីក៏ដោយ អ្នកណាមិនរីកចំរើនដកចេញហើយ សម័យនឹងនោះ ។

ដានី ៖ ដកចេញនឹង ដកទៅ?

វុន ៖ ដកចេញដឹងគេដកយកទៅណា អត់ដឹងរឿងដែរ ។

ដានី ៖ ទៅគ្រប់គ្រងកន្លែងផ្សេង?

វុន ៖ ខ្ញុំអត់ដែរ អីចឹងបានធ្វើអីម្ចាស់ការ ដូចក្រុមគ្រួសារយើង ខ្ញុំតាំងចិត្តមួយថា ខ្ញុំមុននឹងលូកក្តាមលូកឲ្យដល់ឃ្លៀកដូចខ្ញុំរស់នៅសព្វថ្ងៃ បើសិនខ្ញុំធ្វើចំការលេង១ខ្ញុំអត់កាប់បានទេ ដល់៣ហិចតាអត់មានលុយជួរផង តែ២នាក់កូន ។ កូនកំលោះ ហើយនឹងមីងបងទៅបេះសណ្តែកបាត់ហើយ ។ ហើយបើមីកូនតូចមួយនេះ នៅតូចប៉ុនក្អួយវានឹង ។

ដានី ៖ កាលនឹងឮធ្លាប់ប្រជុំ ជាមួយអុំ គាត់មាននិយាយប្រាប់អីថាម៉េចខ្លះ?

វុន ៖ ការប្រជុំ មានរៀនសូត្រការរីកចំរើនទេ ហើយនឹងដូចថាមើលឆ្នាំ៧៧ ៧៨នេះអុំៗឃោសនាតាមសហករណ៍បាយម៉ាថ្ងៃ៣ពេល ។ ប៉ុន្តែឲ្យទៅវិញខ្លះអនុវត្តបាន ខ្លះអត់បានទេ តាមសហករណ៍ ។

ដានី ៖ អត់បានមកមូលហេតុអី?

វុន ៖ បើតាមខ្ញុំសន្និដ្ឋានទៅ ខ្មែរនឹង ខ្មែរក្បត់ កាលជំនាន់នោះច្របូកច្របល់ដែរ ។

ដានី ៖ ក្បត់ម៉េចទៅ?

វុន ៖ ក្បត់វាច្របូកច្របល់វាធ្វើបាបប្រជាជនណា មេៗធ្វើបាបប្រជាជន ។ ចេះថយទៅណាធ្វើបាបដូចថាខ្ញុំគ្រប់គ្រងស្រុកម៉ាខ្សែ ហើយមន្ទីរធំថានៅភ្នំពេញ ហើយខ្ញុំចង់យកមុខយកមាត់ខ្ញុំធ្វើម៉េចប្រជាជនឲ្យហូបខ្វះខាតទៅ ខ្ញុំដើម្បីផ្តល់ទៅនោះ ដើម្បីយកមុខយកមាត់ ។

ដានី ៖ បានន័យថា យើងផលិតបានច្រើន យើងចុះតិចតួចទុកឲ្យប្រជាជន?

វុន ៖ បាទ! ទុកឲ្យតិចតួច ប្រជាជនស៊ីខ្វះខាតទៅ យើងផ្តល់ទៅនោះ យើងរាយការណ៍ថាប្រជាជនខ្ញុំហូបគ្រប់គ្រាន់ហើយ ។

ដានី ៖ ខ្ញុំសល់ច្រើនទៀត ដើម្បីបានគុណសម្បត្តិ?

វុន ៖ បាទ! ដើម្បីបានគុណសម្បត្តិ មុខមាត់ អានេះតាមខ្ញុំវិភាគទេណា ។

ដានី ៖ វិភាគទេ មិនមែន?

វុន ៖ បាទ! មិនមែនឃើញជាក់ស្តែងទេ ប៉ុន្តែខ្ញុំពិសោធន៍កាល៧៨ ខ្ញុំមកលេងសៀមរាប ។ ខ្ញុំឃើញរៀងមើលទើសភ្នែកដែរ កាលនោះប្រកាសម៉ាថ្ងៃ៣ពេលប្រជាជន ព្រឹកបបរ ថ្ងៃបាយ ល្ងាចបាយ ។ ទៅឃើញម៉ែក្មេកខ្ញុំហូបរហេមរហាមដែរ ប៉ុន្តែខ្ញុំអត់ហ៊ាននិយាយ ដល់ខ្ញុំទៅវិញខ្ញុំរាយការណ៍ប្រាប់បានរយៈកន្លះខែ ខ្ញុំរាយការណ៍ទាំងភ័យ នារី១០៥នាក់ ប្រុស៣

នាក់ទេ ខ្ញុំទៅលេងសៀមរាប ឡានទេសចរណ៍ម៉ាគ្រឿងគេជូនមក ។ ដល់ខ្ញុំមកក្ដាប់សភាពការណ៍ គេអត់ឲ្យទៅណា គេឲ្យនៅផ្ទះ ម៉ែក្មេក ប៉ុនមីង១មកខ្ញុំសួរលិចសួរកើត“ក្មួយអើយគេមិនទាន់គ្រប់គ្រាន់ទេ នៅខ្វះខាតនៅឡើយទេ” ខ្ញុំថា“ម៉េចចុះ បើច្បាប់ពីលើគេឲ្យ៣ពេល” “មិនដឹងម៉េចទេក្មួយ” ។ អីចឹងបានខ្ញុំវិភាគបញ្ហានឹង វាមានខ្សែក្បត់ ខ្សែមិនក្បត់ អារឿងខ្សែក្បត់ កាលនឹងវាប្របូកប្របល់ដែរ តាំងពី៧៨មកវាឃ្មួនអុកឡុកនៅឡើយទេកាលនឹង ។

ដានី : ចុះពួរាយការណ៍ប្រាប់ពីណា?

វុន : ប្រាប់នួន ជា ខ្ញុំសរសេរសំបុត្រជូន នួន ជា ។

ដានី : កាលនឹងម៉េចបានពូស្គាល់អ៊ំនួន ជា?

វុន : អ៊ំនួន ជា គាត់រៀនសូត្រនៅខាងលិចស្ដាតបូរីកីឡា ខាងលិចក-៦ មើលខាងលិចស្ដាតមានវង្វង់មូលមួយ ផ្លូវមួយមកពីលិចចេះមកដល់ស្ដាត ផ្លូវនេះចេញពីផ្សារថ្មីមកនេះ អាខាងលិចនេះ ។

ដានី : កន្លែងវង្វង់មូលនាងគង្ហីងនឹង?

វុន : បាទ! ពីមុននាងគង្ហីងបួតសក់នៅនឹង អានឹងកន្លែងបូរីកីឡា កន្លែងតានួន ជាគាត់បង្រៀនហើយ ។ និយាយរួមឲ្យតែកម្មករ ឲ្យតែត្រឹមអនុក្រុម សមាជិកក្រុមយកទៅបង្រៀននៅទាំងអស់ ។ ប៉ុនការបង្រៀន អត់មាននិយាយរឿងស្អី និយាយរឿងរីកចំរើនទេ ។

ដានី : កាលនឹងពូរាយការណ៍ប្រាប់គាត់?

វុន : ខ្ញុំដាច់ចិត្តរាយការណ៍ ។

ដានី : សរសេរសំបុត្រ ឬផ្ទាល់មាត់?

វុន : សរសេរសំបុត្រ ខ្ញុំនិយាយសន្យាជាមួយនារីនឹងឯង ពួកនឹងបើសិនជាមេ១មកចាប់ខ្ញុំ ពួកឯងតស៊ូអត់ នារីថា“ពូខ្ញុំតស៊ូ” មួយឆ្លើយថាតស៊ូ ២ថាតស៊ូ ខ្ញុំសរសេរខ្មោក ផ្ដិតមេដៃ គិតទៅគ្នា១០៥នាក់ ១០៨ទាំងប្រុស៣នាក់ តែ៣នាក់គត់ប្រុស ក្រៅពីនឹងស្រី១ ។ ដល់គេព្រមព្រៀង បានខ្ញុំមានរយៈខ្ញុំមួយនៅក-១២ អានឹងនៅស្រុកជាមួយខ្ញុំឈ្មោះអាឈិត១ នៅប៉ៃលិនរាល់ថ្ងៃ ។ ខ្ញុំថា“ឈិតអើយ! ម៉េច១ចាំប្រាប់ខ្ញុំ គេទៅចាប់ មិនទៅចាប់ប្រាប់១ខ្ញុំណា” បានប្រហែលម៉ោងអាទិត្យជាង អាឈិតមកប្រាប់ថា“គេទៅចាប់បាត់ហើយ បងអើយ” “បានទៅចាប់ធូរហើយ កុំឲ្យគេធ្វើប្រជាជនខ្លាំងពេក” ។

ដានី : ឈិតនឹងគាត់ធ្វើអី?

វុន : ឈិត១គេខាងបើកឡាននារសា ។

ដានី : នារសាពីណា?

វុន ៖ នារសាមេៗ ។

ដានី ៖ នារសាអ៊ីនួន ជា?

វុន ៖ បាទ! ពួកប្អូនខ្ញុំមួយនៅត្រង់នេះ នារសាមេៗដែរ ។

ដានី ៖ អ្នកណាគេ?

វុន ៖ អាប៉េង ។

ដានី ៖ គាត់នៅណា?

វុន ៖ នេះនៅផ្លូវបំបែកភូមិនេះ ភូមិកណ្ដាល ។

ដានី ៖ គាត់នារសាពីណាគេ?

វុន ៖ នៅក-១២ នៅដីកអ៊ីៗទាំងអស់ អ៊ីណាក៏ដោយគេជូនទាំងអស់ ។ ហើយប្អូនខ្ញុំមួយធ្វើការសាលាស្រុករាល់ថ្ងៃ ។

ដានី ៖ ធ្វើការជាមួយអ៊ីដែរ?

វុន ៖ បាទ! នៅជាមួយអ៊ីៗផ្ទាល់ ពីមុននៅប៉ុស្ដិ៍ សម័យដែលរត់យួននោះ នៅប៉ុស្ដិ៍ចិនប៉េកាំង ។

ដានី ៖ ខាងវិទ្យុ?

វុន ៖ បាទ! នៅនេះ នៅតាមចៅហ្វាយខេត្តសុំយកទៅ ប៉ុនស្រុកអត់ឲ្យទៅ ។ មីនោះរឿងផ្សាយវ៉ាដូទាំងប្ដីទាំងប្រពន្ធ មិនបាច់ទេ សំណាំទាំងប្ដីប្រពន្ធ ។ ឥឡូវចៅហ្វាយស្រុកអត់ឲ្យទៅ ឲ្យមីមួយនោះទៅដាច់ដើង ឃោសនាអ៊ីៗតែវ៉ានឹង ពីរនាក់ប្ដីប្រពន្ធ ។

ធានី ៖ ប្ដីប្រពន្ធដែលគាត់ ឈ្មោះអី?

វុន ៖ ជត ស៊្មីជត ទិត ជត ។

ធានី ៖ ទិត ជតនឹង ប្ដី ហើយប្រពន្ធ?

វុន ៖ ប្ដី រឹម ស៊្មីទេ នាមត្រកូលគេភ្លេចបាត់ហើយ ។

ដានី ៖ ប្ដីឈ្មោះ ជត ប្រពន្ធឈ្មោះរឹម?

វុន ៖ បាទ!

ដានី ៖ មួយទៀតឈ្មោះប៉េងនឹង ត្រូវប្អូនពូដែរ?

វុន ៖ ប្អូនខ្ញុំ ។

ធានី ៖ ប្អូនបង្កើត?

វុន ៖ ប្អូនជីទួតមួយ ។

ដានី ៖ ប៉េង ប្រពន្ធគាត់ឈ្មោះអី?

វុន ៖ ឈ្មោះពៅ ។

ដានី ៖ គាត់នៅភូមិកណ្ដាល?

វុន ៖ បាទ! សុទ្ធតែនៅជាប់អឹ១ដែរ ។

ដានី ៖ ឈ្មោះឈិតគាត់អ្នកបើកឡាន?

វុន ៖ អាឈិតបើកឡានក-១២ដែរ ដូចប្អូនខ្ញុំនេះដែរ បើកឡានអឹ១ដែរ ។

ដានី ៖ ឈិតគាត់នៅប៉ៃលិន?

វុន ៖ នៅប៉ៃលិន ។

ដានី ៖ ប៉ៃលិននៅម្ដុំណា?

វុន ៖ នៅឆ្ងាយណាស់ពីនេះទៅ ។

ដានី ៖ ប៉ុន្ដែគាត់នៅកន្លែងណា?

វុន ៖ ដឹងកន្លែងណា ខ្ញុំអត់ដឹងដែរ ខ្ញុំខានទៅយូរដែរ ។

ដានី ៖ គាត់ធ្វើអីឥឡូវ?

វុន ៖ អត់ដឹងដែរ បើពីមុននៅជាមួយអ៊ី ឈានផ្ទាល់ ។ ឥឡូវតាមមើលមិនដាច់ទេមិននៅឆ្ងាយ នៅជាប់អៀង វុទ្ធី អ៊ី ឈាននឹងឯង ។

ធានី ៖ ប្ដីប្រពន្ធ ទិត ជត និងរីមនឹង គាត់រស់នៅកន្លែងណា?

វុន ៖ នៅភូមិកោះ ។

ធានី ៖ ឃុំអីទៅ?

វុន ៖ អេ! ភូមិកោះ មើលភូមិក្បាលស្ពាន អត់សូវដឹងទេ ភូមិអីត្រង់នឹង ប៉ុនហៅភូមិកោះៗ ។

ដានី ៖ នៅឃុំម៉ាឡៃយើង?

វុន ៖ បាទ! ទៅវាមិនសូវដែរទំនេរ ឆាកធ្វើការសាលាស្រុកៗ ។

ដានី ៖ គាត់ប្រាប់ពូថាគេមកចាប់អី ឈិត?

វុន ៖ អូ! ឈិតនឹង ដែលចាប់កាលនោះនៅភ្នំពេញនៅឡើយ ។

ដានី ៖ ប៉ុន្ដែពេលដែលគេសរសេរសំបុត្រសរសេរអី ក្រោយមករយៈពេលប៉ុន្មានបានឈិតប្រាប់?

វុន ៖ រយៈម៉ាអាទិត្យជាងដែរ គេបើកឡានទៅប្រាប់ខ្ញុំ ។

ដានី ៖ បើកឡានថាគេទៅចាប់?

វុន ៖ បាទ! បានថាគេទៅចាប់ធូរហើយ បានរស់នៅស្រួល ខ្ញុំឃើញប្រជាជនលំបាកពេក ចុះរដ្ឋគេប្រកាសតាមវិទ្យុថាម៉ាថ្ងៃ៣ពេល ប្រជាជនសហករណ៍ ដល់ផ្ទុយទៅវិញវាមិនបានប៉ុននឹង ។

ដានី ៖ ចុះម្ដាយក្មេកពូនៅសៀមរាប?

វុន ៖ ខ្ញុំបើនិយាយពីនេះហើយ មុនម៉ែក្មេកខ្ញុំនៅសៀមរាប អានឹងរត់បែកគ្នានៅអន្លង់មៀន ។

ដានី ៖ ឥឡូវដឹងដំណឹងអត់?

រុន ៖ អត់ មានតែដួវម្យ៉ាង មានតែស្លាប់ ។

ដានី ៖ ចុះកូន?

រុន ៖ កូនសម្រាល៧៩ ខ្ញុំអត់ដឹងដែរ មិនដឹងម៉េចណា បើខ្ញុំមកនៅព្រំដែន ខ្ញុំមកដល់គ្រាងបាត់ដល់ខ្មែម ។ បើតាមខ្ញុំមានអី រស់នៅរហូតជាប់គ្នាដែរ គេអ្នកតាម១ គេមកនៅជុំគ្នារហូតទាល់ឥឡូវ ។ ប៉ុនថាចេះទេ រូបយើងវាអត់ រៀងគេវាឆើត មេ១ គេរៀបឲ្យ មិនមែនខ្ញុំនេះទេ ។ ព្រោះមេ១ជំនាន់នឹង តែអ្នកណាការងាររសកម្មគេជំរុញឲ្យហើយប្រពន្ធ ។

ដានី ៖ ពូធ្វើអីកាលនឹង?

រុន ៖ អត់មានធ្វើអីទេ គ្រួសារខ្ញុំ ខ្ញុំត្រឹមប្រធានក្រុម ។

ដានី ៖ គ្រួសារពូមុន?

រុន ៖ គ្រួសារមុនអត់មានធ្វើអីទេ ។

ដានី ៖ ជួបគ្នានៅណា?

រុន ៖ នៅភ្នំពេញ ។

ដានី ៖ នៅភ្នំពេញគាត់ធ្វើការនៅក្រសួងណា?

រុន ៖ នៅកាត់ដេរ ប៉ុនវាមេក្រុមគ្រួសារខ្ញុំ ។

ដានី ៖ បាត់ដំណឹងទល់ឥឡូវទៅ?

រុន ៖ បាត់រហូតទាល់ឥឡូវ សម័យវៀត្នា ខ្ញុំប្រុងសុំកងវរៈដើររក ប៉ុនកងវរៈថា *«មិនបាច់រកទេ ចាំអញទាក់ទងរកឲ្យ»* ចុះឡើងរកថ្មីទៀត ។

ដានី ៖ ឥឡូវពូអត់ដែលបានស៊ើបដំណឹង?

រុន ៖ ខ្ញុំស៊ើបប៉ុនអត់មានចេញ ភូមិខ្ញុំដឹង នៅស្រុកជំដែក ស្រុកសូត្រនិគម ។

ដានី ៖ ស្គាល់ម្តាយក្មេកដែរ?

រុន ៖ ស្គាល់ ។

ដានី ៖ អត់ដែលទៅរកសួរនាំ?

រុន ៖ ខ្ញុំនឹកឃើញវាបើសិនខ្ញុំចុះទៅខ្លាចចុះរកវាមិនឃើញ ខ្ញុំពិបាកដែរ ពីព្រោះខ្ញុំនៅកំពង់ធំ ហើយយើងចុះរក១មិនឃើញមិនអត់បាយ ។ ខ្ញុំចុះសួររកក្មេង១ជិតនឹង ថា *«ទេ! អឹអត់ឃើញទេ គ្រួសារអឹឯង»* ប្រាប់ឈ្មោះ ប្រាប់អីអស់ ។

ដានី ៖ ឈ្មោះអីគេ?

វុន ៖ ឈ្មោះជាតិ ហើយម៉ែឈ្មោះយាយអ៊ុន គាត់មេម៉ាយដែរ ។ ហើយបែកបាក់គ្នារហូតមកទល់ឥឡូវ ដល់ពេលនេះខ្ញុំយកគ្រួសារនេះមក ។

ដានី ៖ គ្រួសារក្រោយរៀបការឆ្នាំណា?

វុន ៖ ការនៅ៨១ ការនៅបន្ទាយទី២ គ្រួសារខ្ញុំមុនបើសិនតាមខ្ញុំរហូតទល់ឥឡូវជួបគ្នាទាល់ឥឡូវ មិនបែកបាក់គ្នាទេ ប៉ុនគេរៀងគ្រាន់គេមិនចង់តាម ។

ដានី ៖ ពេលដែលរត់តាមផ្លូវ គាត់អត់តាម?

វុន ៖ មកបែកគ្នានៅអន្លង់មាន ។

ដានី ៖ ម៉េចបានបែកគ្នា?

វុន ៖ គេអត់ចង់តាមខ្ញុំនោះ ។

ដានី ៖ ចង់ទៅណា?

វុន ៖ គេថាត្រង់ណាច្រើន រត់ទៅត្រង់នឹងឯងផាប់ជុំគ្នាត្រង់នឹង... ។ ហើយបែកគ្នាត្រង់នឹង ស្ងាត់រហូតមក ខ្ញុំចុះមកលិច ។ បើសិនជាមកតាមខ្ញុំដល់នេះ រស់នៅរហូតអត់អីនៅជួបជុំគ្នាទល់ឥឡូវ ។ ខ្ញុំនឹកឃើញថាម្យ៉ាងដូចខ្ញុំនិយាយរូបរាងគេឆើត ឯងវាអន់គេមិនតាមទេ ហើយចិត្តខ្ញុំម្យ៉ាងថាមិនអស់ទេ ស្រីគោករកឯណាមិនបាន នារីគួរសមៗអត់អីគោកស្រឡាញ់ខ្ញុំ ប៉ុនខ្ញុំអត់យកខ្ញុំយកគ្រួសាររាល់ថ្ងៃខ្មៅទេ គ្រួសារខ្ញុំពីមុនសស្អុះ មិនសប៉ុន្មានទេ វាសំបុរសណ្តែតវាគ្រាន់រូបរាងចង្កូរមូល ដល់ក្រោយនេះខ្ញុំរកអន់ ។ ប៉ុនគ្រួសារខ្ញុំរាល់ថ្ងៃមិននិយាយដើមអស់កេរ្តិ៍អស់ខ្មាស់ ខ្ញុំពិសោធន៍ឆ្អែតហើយ គ្រួសារខ្ញុំរាល់ថ្ងៃ ទៅខាងខ្ញុំក៏ដោយទៅខាងម៉ែក្មេកក៏ដោយ ម៉ែខ្ញុំ *«ហើយបើគេសួរថាឲ្យប៉ុន្មានម៉ែ»* *«រកលេខម៉េចឲ្យបានលុយដល់ផ្ទះបានហើយ»* ខ្ញុំនិយាយតែប៉ុននឹងទេ ទៅខាងខ្ញុំក៏ដោយ ខាងនេះក៏ដោយ បងប្អូនគេក៏ដោយខ្ញុំអត់គិតទេ លៃឲ្យគ្រប់ល្មម ខ្ញុំតែប៉ុននឹងអត់មានពិបាកឲ្យប្រពន្ធពិបាកចិត្តអីទេ ថាមកពីប្តីថាំរិតត្បិតត្បៀត ខ្ញុំអត់ត្បិតត្បៀត ។ ហើយម្យ៉ាងគ្រួសារខ្ញុំរាល់ថ្ងៃវាខ្សោយធ្វើអីអត់កើត ឲ្យតែការងារខ្លាំងងាកស្លុះ ។

ដានី ៖ កាលជំនាន់ពតឆ្នាំ ពូដែលមានធ្លាប់ជួយពីណាដែល គាត់មានបញ្ហាអីដែលត្រូវគេចាប់យ៉ាងម៉េច ជួយឲ្យបានរស់ជំនាន់ពតឆ្នាំ?

វុន ៖ ជំនាន់នឹងនោះ ខ្ញុំអត់ទាន់មានអ្នកណាប៉ះពាល់ធ្ងន់កន្លែងខ្ញុំ វាចេះបានថាកន្លែងខ្ញុំអត់មានទាន់ជួយអី ព្រោះអារឿងបញ្ហាចាប់អីនោះវាសំខាន់តាមក្រុមតាមកងទេ ។ បើសិនយើងចេះអនុគ្រោះគ្នា ចេះអធ្យាស្រ័យក្នុងពេលនឹងអត់ងាយចាប់បានទេ វាខូចត្រង់ថាអ្នកមានកំហឹងទល់កំហល់នេះរាយការណ៍ទៅក្រសួង អានឹងគេចាប់មែន ។ ប៉ុនដូចកន្លែងខ្ញុំអត់ទេ អត់មាន ។

ដានី ៖ ពូធ្លាប់ជួយពីណា កាលនៅជំនាន់នឹង?

វុន ៖ វាមានខ្លះដែរ ប៉ុន្តែខ្ញុំចេះអធន់ ចេះអំណត់អត់ធនទៅជួយបានច្រើនដែរ អត់មានអ្នកណាចាប់បានទេ កន្លែងខ្ញុំនោះ ពីព្រោះដូចខ្ញុំនិយាយអីចឹង អ្នកណាខុសតិចតួច ខ្ញុំចេះប្រើងអត់ធ្មត់ ខ្ញុំអត់ហ៊ានរាយការណ៍ទៅមន្ទីរទេ ។ កន្លែងខ្ញុំ វាមានដកទៅខ្លះ ប៉ុន្តែដកទៅទទួលការងារផ្សេង ។

ដានី ៖ ចុះដូចជាចំណីអាហារ បាយទឹក ឬក៏អីមានធ្លាប់ដែលឲ្យគេអត់?

វុន ៖ ជំនាន់នឹង អត់ទេ ជំនាន់រួម គ្មានអ្នកណាឲ្យ ។

ដានី ៖ ចុះពេលវត់?

វុន ៖ វត់អានឹងបានយើងបែងរំលែកចែកគ្នាដែរ យើងជួយគ្នាដែរ ។ ដាក់ស្ដែងខ្ញុំនិយាយ ដែលខ្ញុំចេញពីអមលាំង ដែលខ្ញុំថាចេញពីភ្នំពេញមកអមលាំង ដែលតាម៉ុកគាត់ថា "ឥឡូវពួកក្លួយៗទៅលិច" អានោះខ្ញុំស្មើជីសហករណ៍នៅអមលាំង ខ្ញុំស្មើអង្ករគេបាន៧បាវៗអត់គ្រប់ទៀត ខ្ញុំទៅស្មើនៅកន្លែងតាម៉េត៥០២ ខាងសេនាធិការធំនោះ សេនាធិការភ្នំពេញ តាម៉េតៗ ។

ដានី ៖ ស្គាល់តាម៉េតដែរ?

វុន ៖ ឥឡូវភ្លេចហើយ ខ្ញុំស្មើគាត់បានឲ្យប៉ុន្មាន៣០-៤០បាវ ។

ដានី ៖ គាត់នៅណា?

វុន ៖ កាលនឹងនៅអមលាំង ។

ដានី ៖ គាត់នៅនឹងដែរ?

វុន ៖ បាទ! គាត់នៅនឹងដែរ ។ ដល់ខ្ញុំទាក់ទងបាន គាត់ឲ្យអង្ករបានឲ្យពួកនឹងម្នាក់ម៉ាថៃៗចេញមក ដែលថាខ្ញុំចេញមកដល់ព្រែកជីកដែលខ្ញុំនិយាយដើមដំបូងបានអង្ករនឹងមក ។ មកដល់ព្រែកជីកអត់ទាន់អស់អង្ករទេ មកដល់ឡូត៍ដាច់អង្ករខ្លះ ខ្ញុំស្មើប្រធានសហករណ៍នៅភូមិឡូត៍នោះគាត់ឲ្យ៤០បាវទៀត ។ ចុះមានតិចណាកម្មករៗគាត់ដេរផង កម្មកររោងចក្រផ្សេងៗ ហើយនឹងពេទ្យ១៧ ហើយផ្នែកមន្ទីរ៨៧០ គិតទៅមនុស្សចូល៦០០-៧០០នាក់ គាំងកុមារអីទាំងអស់ ។

ដានី ៖ ចុះប្រជាជនមានដែរអត់?

វុន ៖ ជំនាន់នឹងអត់ទាន់មានទេ បើមានវត់ៗម្ដុំនេះទេ វត់មកព្រំដែន មកម្ដុំព្រៃធំព្រៃអីនេះមានវត់មកព្រំដែនដែរ ប៉ុន្តែកាលមកនោះអត់មានទេ វត់តែកម្មករទេ មកនឹង ។

ដានី ៖ ចុះមកដល់១០២ឆ្នាំណា?

វុន ៖ នៅ១០២នេះ ៨១ ។

ដានី ៖ ៨១មកដល់១០២?

រុន ៖ បាទ! មកដល់១០២ ។

ដានី ៖ ចុះពូមកដល់ឃើញទិដ្ឋភាពយ៉ាងម៉េចដីបូង?

រុន ៖ ១០២ដីបូងនៅព្រៃណែន ព្រៃទាំងអស់ ។

ដានី ៖ ម្តុំណា ដែលពូចូលមកនៅដីបូង?

រុន ៖ ខ្ញុំចូលមកដល់នៅដីបូងនៅកន្លែងភូមិកោះ ដែលខ្ញុំនិយាយនឹង ដែលថាប្អូនខ្ញុំនិយាយ ។

ដានី ៖ ម្តុំភូមិដូង?

រុន ៖ បាទ! នៅនឹងឯង ។

ដានី ៖ កាលនឹងគេហៅភូមិដូងអីចឹង ឬគេហៅអី?

រុន ៖ ភូមិដូងនេះ ភូមិនៅចន្លោះសារតាំង ។

ដានី ៖ ប៉ុន្តែដីបូងគេហៅអីគេពីមុនៗមក?

រុន ៖ គេហៅភូមិដូងនឹងឯងកាលនោះ ។

ដានី ៖ ដីបូងនឹងគេហៅភូមិដូង?

រុន ៖ បាទ!

ដានី ៖ ម៉េចបានគេហៅភូមិដូង?

រុន ៖ មិនដឹងម៉េច វាជិតផ្សារដូងថៃ គេដាក់ភូមិបណ្តោយ ក៏ហៅភូមិដូងរហូត ។

ដានី ៖ ចុះកាលនឹងម៉េចដែរ គេរៀបចំភូមិសាស្ត្រយ៉ាងម៉េចពេលមកដល់១០២ដីបូង ដូចថាកាលន យើងមានកងទ័ព យើងមានខាងនារី?

រុន ៖ បាទ!

ដានី ៖ គេរៀបចំយ៉ាងម៉េច?

រុន ៖ នារីដឹកជញ្ជូននៅ ខ្ញុំចង់ភ្លេចកន្លែងហើយ នៅម្តុំត្រង់ណាភ្លេចកន្លែងបាត់ហើយ នៅច្រកផ្លូវចូលថៃរាល់ថ្ងៃ នៅខាងលិច នៅច្រកនឹងនារីដឹកជញ្ជូន ។ ហើយផ្នែកទ័ពនៅចាប់ផ្តើមអត់នៅនឹងទេ ចេញនៅទីតាំងការពារភ្នំម៉ាឡៃ ហើយបើពួកខ្ញុំចេញទៅនៅបន្ទាយទី២ ។

ដានី ៖ នៅកន្លែងណាបន្ទាយទី២?

រុន ៖ បន្ទាយទី២កន្លែងអូរសំព័រទី២មានស្រះទឹកនោះ សាលារៀនអូរសំព័រទី២ខ្ញុំនៅនឹងឯង ។

ដានី ៖ នៅនឹងរហូត?

រុន ៖ បាទ! ខ្ញុំនៅនឹងរហូតដល់ខ្ញុំពិការអីនឹង ។

ដានី ៖ ពិការដោយសារអី?

រុន ៖ ពិការដោយសារមីន ។

ដានី ៖ ពិការកន្លែងណា?

វុន ៖ ប្រេះអន្ដញ អានេះអំបែង៥ ចេញមួយ នៅ៤នៅក្នុង អាមួយចេញមក អានេះខ្ទាត់៣នៅនេះ ។

ដានី ៖ ត្រូវអន្ដញនឹង ដោយសារមីន?

វុន ៖ ដោយសារមីន ។

ធានី ៖ អត់អីទេ ពូដើរបាន?

វុន ៖ ខ្ញុំពីមុនដើរអត់បានណា ទើបតឡូវខ្ញុំដើរបាន ហើយការដេកពេទ្យយកទៅខាវអ៊ីដាង បារាំងវាសុំវះ តែខ្ញុំថាអត់ឲ្យវះ ហើយមីតូម៉ាមួយវាថា បើវាជនជាតិថៃ តូម៉ានឹងវាទាបជាងមុំទៀត វាថា “បងឯងចង់ទៅផ្ទះវិញ” ខ្ញុំថា “ខ្ញុំចង់ទៅវិញ” បានវាសួរ “ធ្វើម៉េចបានទៅផ្ទះវិញ បងឯងប្រឹងដើរចុះ ថាបើបងឯងដើរបានទៅឡើងឡាន ខ្ញុំឲ្យទៅ” “ខ្ញុំដើរបាន” ដកឈើច្រត់ចេញមុនដំបូងខ្ញុំដើរឈើច្រត់ ហើយជើងអត់សំយ៉ុងបានទេ អាចអន្ដញបានទេតែប៉ុននឹងបាន ខ្ញុំដើរឈើច្រត់ ។ ដល់មីតូណា បើថាឡើងឡានខ្ញុំចេញច្បាប់ឲ្យទៅ ខ្ញុំមានអីឃើញគេតាមជញ្ជាំងឡានមក មិនឆ្ងាយប៉ុន្មានឡានពីនេះទៅគោយន្ដ ខ្ញុំចាប់ផ្ដើមដើរខ្វៗមកឡើងឡាន មកសុំច្បាប់មក ។ តូម៉ាទ្រាំមិនបានសើចៗហើយសរសេរសំបុត្រឲ្យមួយចេញមកបណ្ដោយ ។

ដានី ៖ ចុះកាលនឹងដូចថាពេលសង្គ្រាមពី៨១ កាលនឹងយ៉ាងម៉េចស្ថានភាពហូបចុក?

វុន ៖ លទ្ធភាព អត់មានខ្វះទេ ហើយខ្ញុំរបួសនេះមួយទៀត ខ្ញុំសរសេររាល់ថ្ងៃ មេឃុំឡើងឆ្ងល់ នេះដាច់សរសៃមួយ នេះស្ពឹកម្រាម៣នេះ ហើយប៉ះត្រង់ណាខ្ញុំអត់ឈឺ សរសេររៀងអក្សរគួរសម ប៉ះថ្ងៃណាឈឺចាំមើលរៀងក្រងើកក្រង៉ុកអក្សរ ។ មេឃុំឆ្ងល់ ម៉េចអក្សរមាន២យ៉ាង ។

ដានី ៖ កាលនឹងអត់ខ្វះទេ?

វុន ៖ អត់ខ្វះទេ ។

ដានី ៖ ដូចថាកាលនឹងបានមកពីណា អង្ករ?

វុន ៖ អង្ករចាំមើលខ្ញុំនិយាយណា តាអៀង សារី គាត់ទំនាក់ទំនងផ្នែកកាកបាទហូបចុកបរិបូរ តាំងពីមី ត្រីខ ទឹកដោះគោ ខ្ទាញ់ ហើយអានំចិនដែលខ្ញុំប្រាប់ម៉ាបន្ទុះមាន៤នំ ។ យើងដើរពេលទៅវៃអីទៅមីម៉ាកេះតូចហើយ ស្ពាយទៅម្នាក់ម៉ាកេះៗ៣០កញ្ចប់ ទឹកដោះគោ ។ ប៉ុន្ដែទាហានស្រុកនេះអត់មានស្ពាយគ្រាប់យកត្រៀមខ្លួនស្រេចទេ យកតែម៉ាល្មមរបស់យើងទេ អង្ករក៏អីចឹងដែរ យកតែល្មមទៅ ។ ដល់កន្លែងសំណាក់ត្រង់ណា បើថាសំណាក់ខ្លាំងរាប់តួលេខ ឬគេអូតេមកនាវីដឹកជញ្ជូនយកមកឲ្យ ត្រូវការគ្រាប់បេប៉ុន្មាន អាការប៉ុន្មានឡាំង គេយកទៅឲ្យម៉ង ។

ដានី ៖ កាលនឹងគេធ្វើផ្ទះធ្វើអីនៅ?

វុន ៖ ផ្ទះតូចៗតែ ។

ដានី ៖ ផ្ទះនៅត្រង់ណា?

វុន ៖ ផ្ទះប៉ុនៗនឹង នៅតាមនេះម៉ុំនេះ នារីដឹកជញ្ជូន ហើយនឹងប្រជាជន ។

ដានី ៖ តាមមាត់អូរ?

វុន ៖ បាទ! តាមមាត់អូរតាមផ្លូវ នៅតាំងពីអើយនេះ នៅកន្លែងវាលហាត់រាល់ថ្ងៃ កន្លែងគេហាត់ទាហាន ។

ដានី ៖ ភូមិវាលហាត់?

វុន ៖ បាទ! ភូមិវាលហាត់សាលារៀនរាល់ថ្ងៃកន្លែងហាត់ទាហាន ។

ដានី ៖ ពីជំនាន់ណា?

វុន ៖ សម័យចេញមកពីភ្នំពេញនឹង រាល់ថ្ងៃគេដាក់សាលារៀនវាលហាត់តើ ។

ដានី ៖ ចុះតាអៀងសារីគាត់នៅនឹង?

វុន ៖ តាអៀង សារីគាត់នៅនេះ ហើយសម្ដេចពីមុននៅនេះ នៅសារតាំង ។ រាល់ថ្ងៃឥឡូវទៅមើលគេរៀនចំស្អាតចេះ ជំនាន់ដែលយួនចូលមកអត់ហ៊ានរុះរើណា អាប្រក់ស្បូវម៉េចនៅតែអីចឹង អត់ហ៊ានទេ តែហ៊ានរើផាប់ ។ រាល់ថ្ងៃគេរើចេញធ្វើថ្មី ធ្វើថ្មឥឡូវ ខាងកើតចេះ គេដាក់លោកយាយ ដាក់ព្រះ ។ ហើយកន្លែងដាក់ព្រះគៀនកើតនេះ បត់ជើងតូចផ្ដេសផ្ដាស់ដូរអត់ដឹងកន្លែងបត់ជើង គេដាក់ព្រះភូមិដួលខ្លួនឯង ។

ធានី ៖ នៅកន្លែងណា សារតាំងនឹង?

វុន ៖ កន្លែងសារតាំង យាយសំកាន់នៅកាន់ ។ ឥឡូវសូម្បីសម្ដេចឆ្នាំមិញ ធ្វើកន្លែងហាត់ប្រាណសម្ដេចគាត់ជួយលុយមកប៉ុន្មាន៥០០ដុល្លា រៀបចំ ។

ដានី ៖ នៅកន្លែងសារតាំងនឹង?

វុន ៖ បាទ!

ដានី ៖ ចុះពេលសមាហរណកម្មឆ្នាំណា ៩៦?

វុន ៖ ដឹង៩០ប៉ុន្មានភ្លេចដែរ ។

ដានី ៖ ចុះមុនសមាហរណកម្មយ៉ាងម៉េចដែរ?

វុន ៖ មុនសមាហរណកម្មអត់អី ហូបចុកបរិបូរ ដល់ក្រោយមកសមាហរណកម្មហើយ អានឹងរៀងខ្វះខាតបន្តិចដែរ ដុតពីកាកបាទ រើបំរះរៀងខ្លួន ។ ក្រោយសមាហរណកម្មហើយ ក៏ខ្ញុំអត់បាននៅដែរ ថ្ងៃឡើងទៅហើយរណាដៃមួយចូលព្រៃៗម៉ុំនេះ ។

ដានី ៖ គេចូលធ្វើអី?

វុន ៖ អារឈើ ។

ដានី ៖ អារឈើអីគេ?

វុន ៖ អារឈើយកមកលក់ ។

ដានី ៖ លក់ឲ្យពីណា?

វុន ៖ លក់ឲ្យថៃ ។

ដានី ៖ ហ្នឹងសមាហរណកម្មហើយ?

វុន ៖ បាទ! មុនសមាហរណកម្ម សមាហរណកម្មហើយក៏ដូចគ្នាដែរ ។

ដានី ៖ ដល់ពេល?

វុន ៖ ពេលចេះ ដល់ពេលយើងទៅសមរភូមិមុខយើងទៅ ដល់ពេលយើងមកចាប់ផ្តើមដោះស្រាយជីវភាពប្រពន្ធកូនហើយ ដើម្បីរើបំរាស់ឲ្យរស់ ។

ដានី ៖ ចុះពេលសមាហរណកម្មហើយ យ៉ាងម៉េច គេចែកផ្ទះចែកអីយ៉ាងម៉េច ឬក៏ចាប់ខ្លួនឯង?

វុន ៖ អត់ចែកទេ ឲ្យរកដីខ្លួនចាប់ខ្លួនឯង ។

ដានី ៖ ចាប់ខ្លួនឯងធ្វើផ្ទះខ្លួនឯង?

វុន ៖ បាទ! ខ្ញុំនៅនេះចាប់ខ្លួនឯង ។

ដានី ៖ ចុះដីចំការស្រែ?

វុន ៖ ដីចំការស្រែក៏អីចឹងដែររកខ្លួនឯងទាំងអស់ ។

ដានី ៖ ចាប់បានច្រើន?

វុន ៖ បានតិចដែរ ។

ដានី ៖ បានប៉ុន្មានហិចតា?

វុន ៖ បាន៣ហិចតាដីចំការ ដីស្រែបាន២ ។ ហើយដីស្រែគេឲ្យ៥ហិចតា ឲ្យទៅកូនគេលក់ចោលអស់បាត់ ។

ធានី ៖ គេឲ្យផ្សេងទៀត?

វុន ៖ បាទ! អានឹងគេចែកឲ្យ ។

ធានី ៖ ខាងណា?

វុន ៖ ខាងមេទាហានពួកខ្ញុំ ចែកឲ្យ៥ហិចតា ប៉ុនឥឡូវលក់ចោលបាត់ហើយនៅតាគង់ គេហៅខាងត្បូងតាគង់ ជិតខ្លាយ ។

ដានី ៖ ដល់ពេលសមាហរណកម្មហើយ ពូមានតួនាទីខាងណា កងទ័ព?

វុន : ខ្ញុំសមាហរណកម្មហើយ ខ្ញុំនៅតួនាទីកងទ័ព ។

ដានី : ឋានៈអីដែរ?

វុន : ដឹងឋានៈអីទេ ខ្ញុំនៅជាមួយមេៗ ។

ដានី : ជាមួយពីណាខ្លះ?

វុន : វរសេនាតូច នៅនារសាគេ មេៗដែលធ្លាប់ស្គាល់គ្នាគេយកមកនៅ ។

ដានី : ពីណាគេ?

វុន : ឈ្មោះ សឿម វរសេនាធំសឿម ។

ដានី : វរសេនាតូច?

វុន : វរសេនាតូចជំនាន់នោះ មិនដឹងពីណា ខ្ញុំនៅជាមួយមេៗជាមួយសឿមវរសេនាធំនឹងឯង ។

ដានី : ដល់ពេលយើងសមាហរណកម្មហើយ យើងរកខ្លួនឯង ហើយកាលពីមុន យើងមានកាកបាទ ផ្គត់ផ្គង់ ខុសគ្នាយ៉ាងម៉េច ពីឥឡូវពីមុន?

វុន : ខុសគ្នាដែរ ខុសគ្នាត្រង់ថាពីមុនផ្នែករដ្ឋាភិបាលគេឧបត្ថម្ភតាំងពីអង្ករស៊ីចុកគ្រប់គ្រាន់ទាំងអស់ អត់មានបើកប្រាក់ខែអីទេ អត់មានលុយខែ ដូច្នេះកូនចៅគេគិតរបបអង្ករឲ្យ ។ របបក្នុងមួយខែហូបមួយគ្រួសារ អត់អស់ទេម៉ាខែនឹង សល់ ។ ហើយយើងយកអង្ករនឹងយើងយកដូរអីខ្លះ ហើយយើងឆ្លៀតរកអារឈើរួមផ្សំគ្នាទិញជាម្ហូបចំណី ។ ដូច្នេះវាចុះថយពីជំនាន់កាកបាទដែរ អានឹងចាប់ផ្តើមបែកគំនិតរៀងដើម្បីដោះស្រាយជីវភាពកូនចៅ ។ ប៉ុនអង្ករនៅតែឲ្យទេ ប៉ុនវាអត់មានអំបិល ប្រហុក ប៊ីចេង ស្ករ របស់របរផ្សេងៗគេអត់ឲ្យគេឲ្យតែអង្ករ ហើយខោអាវក៏អត់ឲ្យដែរ យើងដោះស្រាយខ្លួនយើងហើយ គេឲ្យតែអង្ករ ។ បានថាវើបំរាស់រៀងខ្លួន រហូតដល់សមាហរណកម្មរួច ២-៣ឆ្នាំនោះដាច់អង្ករផុតៗ ខ្ញុំដោះស្រាយខ្លួនឯងបានធ្វើស្រែខ្លួនឯងបាន ម៉ាវ៉ែ២វ៉ៃ ដោះស្រាយបានធូរ ។

ដានី : ចុះអ្នកផ្សេងៗទៀត?

វុន : ផ្សេងៗក៏អីចឹងដែរ ច្រើនវើបំរាស់ រាល់ថ្ងៃនេះ អ្នកដែលនៅនេះចាស់ភាគតិចដែលអត់ៗមក ពីគេមិនគិតគូរចាប់អារម្មណ៍ ។

ដានី : បានន័យថាគេអត់សូវប្រើងប្រែង?

វុន : អត់ប្រឹងប្រែង បានន័យថាយើងខ្ជិលចង់ធ្វើអីដើរលេង ។ ហើយអ្នកដែលគេមិនសូវអត់ឃ្លាន មូលហេតុអី មូលហេតុគេប្រឹងប្រែងដូចខ្ញុំអីប្រឹងប្រែងវើបំរាស់មែនទែន ទម្រាំបានអាកញ្ចាស់ខ្ញុំម៉ាគ្រឿងនេះ ចង់ដាច់ខ្យល់ហើយ ។

ដានី : អាត្រាក់នឹង?

រុន ៖ គោយន្ត ។

ដានី ៖ បើតាមយោបល់របស់ពូៗគិតថា ការសមាហរណកម្មហើយស្រួលជាងកាលពីមុន ឬក៏ពីមុនស្រួលជាង?

រុន ៖ និយាយរួមមុនសមាហរណកម្មស្រួល វាធូរចិត្តជាង ធូរចិត្តយ៉ាងម៉េច ធូរចិត្តត្រង់ថាបើថាទៅសមរភូមិៗគិតសមរភូមិមុខ អារឿងអន្តរអីបើកឲ្យអត់មានគិតគូររឿងកូនចៅទេ ។ ប៉ុន្តែមកសម័យយើងឥឡូវ បើសិនជាទៅណាទៅណែគិតអារម្មណ៍រឿងកូនចៅអត់ឃ្លាន ពីមុនអត់មានពិបាកទេ ជំនាន់បើកអន្តរ ។ យើងមានទៅគិតអី យើងទៅមុខបាត់ ប្រពន្ធកូនដល់ផ្ទះគេបើកឲ្យហើយ តាំងពីប៊ីចេង ឲ្យម៉ាចប់ អត់ប្រាក់ខែមែន ប៉ុនស៊ីចុកទាំងអស់លើរដ្ឋាភិបាល ។

ដានី ៖ ចុះម៉ាឡៃយើងកាលពីមុន ពេលពូមកដល់កន្លែងនឹងម៉េចដែរ?

រុន ៖ ពីមុនមកនៅព្រៃដូចខ្ញុំថាវាម្ដុំកន្លែង ។

ដានី ៖ នៅក្នុងស្រុកអីដែរ?

រុន ៖ អានេះពីដើមនៅបាត់ដំបង ពីមុន ។

ដានី ៖ ប៉ុន្តែស្រុកអី?

រុន ៖ មិនដឹងស្រុកអី ខ្ញុំអត់ដឹងដែរ អាចចូលស្រុកអូរជ្រៅ ។

ដានី ៖ អូរជ្រៅតំបន់ប៉ុន្មានពីជំនាន់ខ្មែរក្រហម?

រុន ៖ អត់ដឹងដែរ ខ្ញុំ ។

ដានី ៖ តំបន់៥ ក៏តំបន់៣?

រុន ៖ អត់ដឹង ប៉ុននេះកាលដែលជំនាន់យួននៅនេះ គេដាក់តំបន់១០២ ។

ដានី ៖ ចុះពេលសមាហរណកម្ម គេចែកភូមិឃុំយ៉ាងម៉េច កាលពីមុនមកយើងមិនដែលមានឈ្មោះអីចឹង ដល់ពេលក្រោយមកគេដាក់ឈ្មោះនេះៗ ភូមិកណ្ដាល ភូមិក្បាលស្ពាន ភូមិវាលហាត់ ភូមិថ្មី អានឹងម៉េចបានគេដាក់អីចឹង?

រុន ៖ ខ្ញុំអត់ដឹងដែរ លើគេអ្នកគ្រប់គ្រង ជាពិសេសខាងផ្នែកទាហាន ពីមុនអត់មានភូមិឃុំអីទេ លើមេៗគេរៀបចំនោះ ដូចភូមិខ្ញុំគេដាក់ភូមិថ្មី នោះភូមិដំបូកវិល ភូមិវត្តចាស់ ភូមិត្រសេកជ្រុំ ភូមិក្បាលស្ពាន ភូមិកណ្ដាល ភូមិវាលហាត់ មាន៨ភូមិ ។

ដានី ៖ ឈ្មោះអត់ដឹងដែរ?

រុន ៖ គេទើបរៀបចំដែលសមាហរណកម្មហើយទេ គេបង្កើតនោះ ។

ដានី ៖ ដូចភូមិសាស្ត្រផ្សេងៗ ដូចឈ្មោះភ្នំ អូរចុះឡើងពេលសង្គ្រាមគេដាក់ឈ្មោះច្រើន?

រុន ៖ មានគេដាក់ច្រើន ដូចគេហៅអូរចោទៗ អាផ្លូវថៅកែយ៉ាវខាងនោះភ្នំយាយសំនោះ អានឹងគេហៅអូរចោទ អូរលោត ចេះដាក់ទៅណា ដាក់ផាវ ។

ដានី ៖ ពេលសង្គ្រាមនឹង?

រុន ៖ បាទ!

ដានី ៖ ពេលសង្គ្រាមឆ្នាំ៧៩ ៨០?

រុន ៖ បាទ! ដូចនៅគ្រាងនេះ គេហៅអូរភ្លើងឆេះ អូរនឹងមិនដឹងអូរអីទេ អូរថៃ អត់ដឹងទេ ប៉ុនដល់ពួកខ្ញុំទៅនៅនឹងឃើញភ្លើងឆេះៗព្រៃ គេដាក់អូរភ្លើងឆេះទៅ ។

ដានី ៖ ដូចឈ្មោះភ្នំរូង ភ្នំអីណាភ្នំទឹកចេញ?

រុន ៖ ភ្នំរូងអានឹង ភ្នំទឹកចេញ អាភ្នំនឹងទឹកវាចេញពីមុនៗ ដូចភ្នំរូងនេះមានរូងតើ ឥឡូវគេលុបចោលអស់បាត់ ។

ធានី ៖ រូងពីណាទៅ?

រុន ៖ រូងនៅក្នុងនឹង ។

ដានី ៖ យើងដាក់ខ្លួនឯង?

រុន ៖ បាទ! ដាក់ខ្លួនឯង ដូចភ្នំ៩៣នេះ គឺទាហានយួនមកនៅ១៩៩៣ អាវត្ត៩៣រាល់ថ្ងៃនេះភ្នំរូងក៏អីចឹងដែរ យួនធ្វើរូងនៅ ។ ប៉ុនបើបារាំងធ្លាក់អានឹងថៃវាដាក់ផាវទេ បារាំងធ្លាក់ ថៃវានិយាយភាសាវាបារាំងតុកតាយ បារាំងធ្លាក់ផាប់បកប្រែភាសាយើង ។ រួចអូរចោទនោះក៏យកតាមភាសាថៃដែរ ភ្នំ៥៣នោះ ឡាក់យើងនៅពាក់កណ្តាលភ្នំ៥៣ដែរ ប៉ុនថៃវាដាក់ភ្នំ៥៣ដែរ ។

ធានី ៖ ម៉េចបានថៃអ្នកដាក់ឈ្មោះទៅវិញ?

រុន ៖ កាលនោះ យើងនៅនេះអត់ដឹងទេ ច្រើនតែអ្នកដែលចុះមកពីភ្នំពេញដូចខ្ញុំអីវាអត់ដឹង វាអត់ដឹង ដល់ភ្នំ៥៣តាមថៃនិយាយយើងចេះនិយាយតាមនឹងទៅ ។

ធានី ៖ ថៃមកពីណា?

រុន ៖ ថៃវាមកជួបនិយាយទាក់ទងយើង ។

ដានី ៖ ពូឆ្នាំណាបានពូត្រឡប់ទៅលេងផ្ទះ?

រុន ៖ ទៅលេងស្រុក ខ្ញុំនិយាយរួមតាំងពីបែកមកខ្ញុំទើបទៅមើលទៅ៩៧ ។

ដានី ៖ ទើបទៅលើកទី១?

រុន ៖ លើកទី១ទាំងអស់ ។

ដានី ៖ តាំងពីបែកចេញពីផ្ទះតាំងពីឆ្នាំ៧០ប៉ុន្មាន?

រុន ៖ តាំងពី៧២មក ។

ដានី ៖ តាំងពី៧២មកដល់ឆ្នាំ៩៧បានទៅផ្ទះលើកទី១ ?

រុន ៖ បាទ! ចាំមើលខ្ញុំនិយាយអាលើកទី១វេទនាទម្រាំទៅដល់ មើលទៅដល់កំពង់ធំម៉ោង៨យប់បានដល់ ទៅពីនេះទៅដាប់បន្ទាយមានជ័យ ហុចសំបុត្រអនុញ្ញាតិពីលោកសុខ ភាព ឲ្យគេមើល ៗ ហើយគេពិនិត្យឡានលិចកើត ៗ កាលនោះខ្ញុំទៅតែ៣នាក់គត់ តែកូនខ្ញុំអាប្រុសមួយ ហើយនឹងអាប៉េងនឹង ទៅដល់ខត្តុគ្គពួកប៉េអ៊ឹមគេរកដកកាំភ្លើង កាលនោះពួកខ្ញុំយកអាការម៉ាដើម កាំភ្លើងខ្លីម៉ាដើមទៅ ។ ហើយកាលនោះ ជំនាន់នោះគេមានបាតុកម្មនៅភ្នំពេញ វាមានសកម្មភាពអស់ស្រួលភ្នំពេញ គិតតាំងពីម៉ោង១១មកទល់ម៉ោង២បានសម្រេចឲ្យទៅនិយាយជជែកវែកគ្នាចុះឡើង ៗ ទាល់តែឲ្យគ្រាប់កាំភ្លើងខ្លីអស់១០គ្រាប់បានគេឲ្យទៅ ។ ឆ្លងព្រែកក្តាមទៅដល់កំពង់ចាម ទៅដល់ភ្នំបាធាយបែកកង់ឡានមួយរបស់អាឆ្នូយ ៗ ស្ងាប់បាត់ហើយប៉ះកង់ហើយចេញទៅលិចទៀត ទៅដល់...យប់សួរ *"អ៊ំមានគេប្លន់គេអីអត់ពីនេះទៅកំពង់ធំ"* *"អត់អីទេក្មួយចេញទៅ"* ហើយខ្ញុំត្រៀមដាប់ហើយអាការហើយនឹងកាំភ្លើងខ្លី ខ្លាចមានចោរគេបាញ់គេអី ។ ទៅដល់កំពង់ធំម៉ោង៨ កាលនោះមានលុយហើយអត់បាយទៀត អត់មានអ្នកណាលក់បាយចុះឡើង ៗ ទៅរកនំបញ្ចុកហើយនឹងពងទានឹង ដេកអត់បាយមួយយប់ ព្រឹកឡើងបានចេញទៅសណ្តាន់ ។

ដានី ៖ សណ្តាន់នៅភូមិអីគេ?

រុន ៖ ភូមិមានឫទ្ធិ ឃុំមានឫទ្ធិ ។

ដានី ៖ ហើយម៉េចទៅ?

រុន ៖ ហើយជំនាន់នឹងថាឡានដាប់ខ្សាច់ហត់ចង់ងាប់ គ្នាតែ៣នាក់តែខ្ញុំ ប្អូនខ្ញុំ ហើយនឹងកូនខ្ញុំវាអ្នកបើក ទៅដាប់ឡាន ។ ចេញពីកំពង់ធំទៅ ៗ ហួសកន្លែងខាងកើត...ដាប់ដីខ្សាច់នៅនោះ មិនដឹងធ្វើម៉េច *"ឯងយកដែកដុយមកអត់?"* *"ថាយកមកបង"* ខ្ញុំទៅរកធាងត្នោតមក ខ្ញុំដាក់ឌុយហើបហើយ ខ្ញុំយកស្លឹកត្នោតដាក់ពីក្រោមបានបើកចេញផុត ។ ទម្រាំដល់ទៅម៉ោង១១ដល់សណ្តាន់ ម៉ោង១១ថ្ងៃចេញតាំងពីព្រឹក ។ ទៅដល់នោះ អត់មានពីណាដឹងទេ ខ្ញុំវង្វេងផ្ទះហួសផ្ទះជិត១០០ម៉ែត្រ បកសួរគេទៅផ្ទះបងឯងនៅក្រោយបានចូលផុត ។ គ្រាន់ចូល គ្មានបានចេញទៅណារួចទេ នៅលើផ្ទះ បត់ជើងតូចរកចុះមិនរួច ដើរទៅណាមិនរួច ផ្ទះខ្ញុំ២ខ្នង៨-៩ឡើងណែន ស្គាល់អញទេ អត់ទេអត់មានអ្នកណាស្គាល់ ។

ដានី ៖ អត់ស្គាល់ទាំងអស់?

រុន ៖ អត់ទាំងអស់ចំណាំបានតែមុខ ។

ដានី : ដូចបងប្អូនបង្កើត?

វុន : បងប្អូនបង្កើតចំណាំបាន ស្គាល់ឈ្មោះ បើមីពៅខ្ញុំកាលខ្ញុំបែកមក អត់ដឹងទេ ដឹងថាប្អូនឯងបង្កើត អត់ដឹង ។

ដានី : អត់ទាន់កើត?

វុន : បាទ! ទើបចេញមកអត់ទាន់កើតផង អត់មានដឹងថាប្អូនអីទេ ។ ប៉ុននោះដឹងថា ខ្ញុំផ្ញើរូបថតទៅ ឃើញអោបក្រឹបបងអញៗ វាយំ ខ្ញុំទំទប់ដែរណា ។

ដានី : បែកលើកដំបូង?

វុន : បាទ!

ដានី : ចុះឪពុកម្ដាយ?

វុន : ពុកខ្ញុំខូចបាត់ហើយ នៅតែម្ដាយ គិតទៅប្អូនអោបក្រឹប ប្អូនយំហូរ ខ្ញុំទំទប់ៗទាំងទឹកភ្នែក ទប់ទាំងពាក្យសម្ដី វាដូចអាណោចអាធម៌ពេក វាហួសចិត្តមិនដឹងធ្វើម៉េច ។

ដានី : ដូចអារម្មណ៍របស់ពូ ដូចថាកាលពីក្មេងៗពូធ្លាប់នៅស្រុកភូមិនៅជាមួយបងប្អូនជាមួយញាតិមិត្ត ហើយមិត្តភ័ក្ដនៅក្នុងភូមិ ដូចថាយើងមានអារម្មណ៍ជិតស្និតជាមួយគ្នាកាលពីក្មេង ដល់ពេលពូបែកយូរហូតមកដល់ពូមកនៅនេះយូរ កកើតអ្នកដែលមកពីកន្លែងផ្សេងមកជួបជុំគ្នា មករស់នៅជាមួយគ្នាមានអារម្មណ៍ជិតស្និតអីចឹង ដល់ពេលយើងទៅផ្ទះវិញ ពេលយើងទៅលេងផ្ទះអីចុះមិត្តភ័ក្ដពូ អ្នកដែលធ្លាប់ស្គាល់គ្នា ញាតិមិត្តកាលនៅតូចៗ ពូទៅវិញមានអារម្មណ៍ម៉េចដែរ ពេលទៅជួបគាត់?

វុន : អត់អីទេ មានអារម្មណ៍ជួបគ្នារៀងសប្បាយ ។

ដានី : ពួកគាត់មានអារម្មណ៍ជិតស្និតដូចគ្នា?

វុន : ជិតស្និតដូចគ្នា នៅដដែលអត់ប្លែកទេ គ្រាន់តែឃើញខ្ញុំទៅអាខ្លះយកមាន់ យកអីភាគច្រើនស្រុកនោះគេច្រើនយកតែស្រា ដាក់ជាមុខ ។ ខ្លះឯងមានអី ខ្លះមាន់ ចាប់ផ្ដើម ពេលល្ងាចខ្ញុំទៅដល់ គេត្រៀមស្រេចហើយ ហូបម៉ាសារ ដល់ពេលខ្ញុំរៀបបែកមកទៅទៀតហើយ ។

ដានី : ទៅប៉ុន្មានថ្ងៃ?

វុន : ខ្ញុំទៅជួនកាលកន្លះខែ ជួនកាលម៉ាខែ អត់ដែលទៅយូរទេ ។

ធានី : ពូខស្សាហ៍ទៅដែរ?

វុន : ខ្ញុំទៅរាល់ឆ្នាំ ។

ដានី : ទៅរាល់ឆ្នាំ?

វុន : បាទ! គ្រាន់វស្សាមិញនេះ ម៉ែឈឺខ្ញុំទៅៗបាន៦ថ្ងៃទៅមក ។

ដានី ៖ ដូចថាអារម្មណ៍របស់ពូនៅស្រុកកំណើត ហើយឥឡូវនៅម៉ាឡៃ មានលក្ខណៈស្និតស្នាល ខុសគ្នាយ៉ាងម៉េច?

វុន ៖ ទេ! បើនិយាយទៅដូចធម្មតាទៅវិញ មកនៅនេះដូចភូមិស្រុកឯង ទៅនោះដូចភូមិស្រុកឯង ។

ដានី ៖ នេះក៏ដូចភូមិស្រុក នោះក៏ដូចភូមិស្រុក?

វុន ៖ បាទ!

ដានី ៖ ពូចង់ទៅណាជាង?

វុន ៖ ចិត្តដូចខ្ញុំថានៅនេះ ងាប់រស់នេះ ។

ដានី ៖ មូលហេតុអី?

វុន ៖ មូលហេតុអីយើងទៅនោះដណ្ដើមដីបងប្អូនវាយ៉ាប់ បើយើងនៅនេះដីធ្លីយើងរស់នៅនេះបានស្រួល ដីវាតិចមែន ប៉ុនធ្វើស្រូវកើត ។ នេះបើដីខ្ញុំរាល់ថ្ងៃ បើសិនភ្លៀងបរិបូរ ខ្ញុំធ្វើបាន ៦០បាវជាង ៗមិនមែនអាបាវយើងតូចតាច អាបាវបង្កោលអា៧តៅ ៦០បាវជាង ហើយពូជអត់ច្រើនទេ ពូជអស់តែ៤តៅទេ២ថាំងហើយ ៗ ។ អីចឹងបានខ្ញុំថាទៅនៅនោះ គេស្នងប៉ុននេះមួយ ខ្ញុំគ្រវីក្បាល ។

ដានី ៖ ដូចថាអារម្មណ៍ពីការជិតស្និតវិញ អ្នកដែលធ្លាប់រស់នៅពីនេះពីមុនមក ហើយឥឡូវវាខុសគ្នាយ៉ាងម៉េចដែរ ចិត្តពូ?

វុន ៖ អ្នកដឹកនាំនៅនេះ និងនៅនោះ?

ដានី ៖ អត់ទេ ដូចថាអ្នកជិតខាង មិត្តភ័ក្តដែលធ្លាប់នៅអន្តភាពពីមុនមកឥឡូវក្លាយជាអ្នកជិតខាងពូនៅនេះ?

វុន ៖ អានឹងបើនិយាយទៅដូចបងប្អូនរាល់ថ្ងៃ ដូចផ្ទះរៀប ផ្ទុះអីនេះ គេឈឺថ្កាត់ ខ្ញុំទៅអើតមើលគេសួរនាំទៅ បើខ្ញុំវិញគេមកសួរនាំ និយាយរួមសុទ្ធតែម៉ាជុំវិញទាំងអស់ សុទ្ធតែសួរនាំគ្នា ។ គ្មានស្អីទេ មានតែសណ្ដានចិត្តសួរនាំ ហើយឧទាហរណ៍ថាយើងលើកផ្ទះលើកសម្បែងអីទៅរកគេ ៗមកជួយ អត់មានឲ្យអស់លុយកាកទេ គេមកជួយម៉ង យើងគ្រាន់តែចំណាយបាយទឹកឲ្យគេហូប វាស្រួលអីចឹង ។ បើនិយាយទៅការរាប់អានបងប្អូនបង្កើតវាសឹងមិនស្មើអាញាតិជិតខាងផង នេះខ្ញុំនិយាយឲ្យត្រង់ ប៉ុនដោយឡែកបុគ្គលទេណា ។ ដូចរៀបអីនេះ គ្រាន់គោយន្តខ្ញុំហ៊ា ថាចង់រកទៅជួយដើររក ជួយស្ដាប់សម្លេងស្ដាប់អី ។

ដានី ៖ ចុះសព្វថ្ងៃ ពូកាលមុនពួកខ្ញុំមកម៉ាសារទាក់ទងពីតុលាការ កាលនឹងពូយល់ឃើញម៉េចដែរចំពោះតុលាការដែរគេ តើសព្វថ្ងៃដែលគេកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម?

រុន ៖ អានឹងខ្ញុំនិយាយទៅអត់បញ្ហា អានឹងជាការកំហុសឆ្គងរបស់គាត់មេៗ ពីព្រោះការដឹកនាំ នៅមេឃឈើណាស់ខ្ពស់វាតែងច្បាស់ហើយណា ខ្យល់បក់ត្រូវហើយ ។ ហើយយើងដែលទាបអត់មានបញ្ហាអី ខ្ញុំអត់មានទោមនស្សអីទេ អានឹងជាការកំហុសរបស់គាត់ ។ បើនិយាយរឿងច្បាប់ក៏អីចឹងដែរ ការរៀបចំច្បាប់ខ្ញុំអត់មានយល់ទាស់អីដែរ អត់មានទោមនស្ស រៀបចំដើម្បីថែរក្សានៅក្នុងសង្គម ។

ដានី ៖ ខ្ញុំដូចជាអស់សំនួរ ។

ធានី ៖ ពូមានឈ្មោះអីដែរ?

រុន ៖ ខ្ញុំឈ្មោះ អ៊ុល រុន ។

ធានី ៖ ឆ្នាំនឹងពូអាយុប៉ុន្មាន?

រុន ៖ នៅវាចូល៥៩ហើយ ។

ធានី ៖ រាល់ថ្ងៃពូរស់នៅភូមិឃុំណាដែរ?

រុន ៖ នៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ។

ធានី ៖ ពូមានមុខងារធ្វើអីដែរ?

រុន ៖ ប្រធានភូមិ ។

ធានី ៖ ពូធ្វើប្រធានភូមិតាំងពីឆ្នាំណា?

រុន ៖ ខ្ញុំទើបធ្វើបានម៉ាឆ្នាំនេះទេ ។

ធានី ៖ ឪពុកពូឈ្មោះអី?

រុន ៖ ឪពុកខ្ញុំឈ្មោះ អ៊ុល សិត ។

ធានី ៖ គាត់ស្លាប់ពេលណា?

រុន ៖ អត់ដឹងដែរ ខ្ញុំ ។

ធានី ៖ ចុះម្តាយ?

រុន ៖ ម្តាយឈ្មោះខៀវ ជី ។

ធានី ៖ គាត់នៅរស់?

រុន ៖ នៅរស់ នេះម៉ែខ្ញុំ នេះម៉ែក្មេក ។

ធានី ៖ ពូបានរៀនសូត្រអីទេ?

រុន ៖ ខ្ញុំរៀនពីសង្គមបានថ្នាក់ទី១០ បើនិយាយស្មើថ្នាក់ទី៣ឥឡូវ ។

ធានី ៖ ប្រពន្ធសព្វថ្ងៃឈ្មោះអីគេ?

រុន ៖ ជា ធី ។

ដានី ៖ គាត់អ្នកស្រុកណា?

វុន ៖ នៅខត្តក្តក ។

ដានី ៖ នៅខត្តក្តក់ម៉េច?

វុន ៖ នៅភូមិត្រពាំងទុំ ឃុំវាលថ្គង់ ស្រុកខត្តក្តក ខេត្តកំពង់ស្ពឺ ។

ធានី ៖ សព្វថ្ងៃពូមានកូនប៉ុន្មាននាក់?

វុន ៖ ៣ ។

ធានី ៖ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

វុន ៖ ស្រី២ ប្រុស១ ។

ធានី ៖ ពូមានបងប្អូនប៉ុន្មាននាក់?

វុន ៖ បងប្អូនខ្ញុំ៤នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

វុន ៖ ប្រុស៣ ស្រីមួយ នៅស្រុកកំណើត២ បែក២ បែកខ្ញុំហើយនឹងប្អូនខ្ញុំនៅកំពង់ស្ពឺ នៅព្រំប្រទល់តាកែវ ។

ធានី ៖ ពូមិញ ពូថាតាចៀមបានជួយពូពេលពូនៅពោធិ៍សាត់ តាចៀមគាត់អ្នកណាគេ ហើយគាត់មកពីណា?

វុន ៖ គាត់ តាចៀម ខាងភស្តុភា ។

ដានី ៖ ភស្តុភារនៅ?

វុន ៖ គាត់ខាងភស្តុភារផ្គត់ផ្គង់ អន្តរហូបចុកអីនឹង ។

ដានី ៖ នៅ១០២?

វុន ៖ បាទ!នៅនេះ ។

ធានី ៖ ចុះមុនពូថារត់មក?

វុន ៖ រត់មកជួបតាចៀម គាត់រៀបចំកម្លាំងមកនោះមក រត់នៅភូមិឯងនៅព្រែកជីកដែលខ្ញុំនិយាយដែលខ្ញុំនិយាយនោះ កម្លាំងម៉ាវរសេនាតូចមក តានីគាត់អ្នកដឹកនាំមក ហើយតាចៀមគាត់អ្នកមេធំ ។

ធានី ៖ តែតាចៀមនឹងពូដឹងថា ពីមុនគាត់ធ្វើអី ហើយម៉េចបានគាត់អ្នកដឹកនាំ?

វុន ៖ គាត់តាចៀមពីមុនស្អីទេ ខ្ញុំមិនសូវដឹងដែរ ផ្នែកក្រសួងការបរទេស តួនាទីខាងអីខ្ញុំអត់ដឹងដែរ បើតានី គាត់ទទួលវរសេនាតូច ។

ធានី ៖ ពូដឹងថាតាចៀមគាត់នៅណារាល់ថ្ងៃ?

វុន ៖ នៅនេះ នៅ ។

ធានី ៖ នៅភូមិឃុំអីគេ?

វុន ៖ នៅភូមិដូង អូ!ភូមិវាលហាត់ ។

ធានី ៖ គាចៀមគាត់ជនជាតិនឹង?

វុន ៖ ជនជាតិ ដឹងជនជាតិអីទេ ខ្ញុំអត់ដឹងដែរ និយាយប៉ៃឡាំ បើថា១០០ចេះ គាត់សរសេរលេខ ១០០ហើយ បានគេសរសេរលេខ១០ទៀត នឹងប្រវត្តិគាត់ ។

ធានី ៖ ភូមិវាលហាត់ ឃុំម៉ាឡៃយើងដែរ?

វុន ៖ បាទ! ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ។

ធានី ៖ ពូមានលេខទូរស័ព្ទទេ?

វុន ៖ ខ្ញុំ០៧៧ ២១ ៦៦ ៥៣ ។

ធានី ៖ មានលេខមួយទៀត?

វុន ៖ អត់មានទេ មានតែមួយ អត់មានប្រែប្រួល ។

ធានី ៖ ពូខ្ញុំសុំយកសម្លេង ក៏ដូចជារូបថត ដែលពួកខ្ញុំបានថត ហើយអ្វីដែលពូបានរៀបរាប់មិញ យកទៅធ្វើជាសៀវភៅ និងសម្រាប់ក្មេងៗក៏ដូចជាអ្នកស្រាវជ្រាវផ្សេងៗយកមកសិក្សារៀន សូត្របានទេ?

វុន ៖ ចុះមានអី ។

ធានី ៖ អរគុណពូច្រើន ។

វុន ៖ បាទ!

«ចប់»